**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៊ម តំបន់ទី ៥

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃព្រហស្បតិ៍ ទី១៧ ខែសីហា ឆ្នាំ២០០៦**

**ខេត្តពោធិ៍សាត់**

**ខប់សែល ដំណាក់កាលទី ២**

COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈ**

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក ឡារី ស្ត្រេន្ទ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឌិក សេរី សោភក្តិ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតថ្លែងដោយលោក ផាន់ វណ្ណសិទ្ធិ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តពោធិ៍សាត់

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តពោធិ៍សាត់

៥. សេចក្តីផ្សេងៗ

---

## ១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក ឡារី ស្ត្រេន្ទ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **លោក ឡារី ស្ត្រេន្ទ** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្ហាញគ្រួសៗថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI រៀបចំកម្មវិធីខប់សែលនេះឡើង វិទ្យាស្ថាន CDRI គឺជាស្ថាប័នមួយធ្វើការស្រាវជ្រាវដោយឯករាជ្យ ដែលយើងបានស្រាវជ្រាវ ទៅលើគោលនយោបាយផ្សេងៗ ហើយមិនពាក់ព័ន្ធទៅនិងនយោបាយ ឬ គណបក្សនយោបាយណាមួយឡើយ ។ វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវទៅលើវិស័យ៥ ដែលជាវិស័យសំខាន់ៗនៅក្នុងការជំរុញ ឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលមានដូចជា សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ពាណិជ្ជកម្ម ការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ការកាត់ បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍វិស័យកសិកម្មជនបទ ការអភិវឌ្ឍន៍ជីវភាពរស់នៅ អភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិបតេយ្យ កំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន សន្តិសុខមនុស្ស និងការដោះស្រាយទំនាស់ ។ ជាទស្សនៈ វិស័យរបស់វិទ្យាស្ថាន CDRI ដើម្បីឱ្យវិស័យទាំង ៥ ដំណើរការប្រកបដោយ ភាពរលូន និងល្អ យើងត្រូវការចាំបាច់ណាស់នូវការ កសាងលទ្ធិប្រជាធិបតេយ្យមួយឱ្យបានរឹងមាំ និងពិតប្រាកដក្នុងប្រទេសកម្ពុជា ដោយមើលឃើញពីសារៈសំខាន់នេះហើយបានជា វិទ្យាស្ថានបានព្យាយាម និងធ្វើការជាមួយភាគី ពាក់ព័ន្ធនានា ជាពិសេសជំរុញរឿងការងារបោះឆ្នោត ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមាន ការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ដោយគ្មានហិង្សា ព្រមទាំងមានវប្បធម៌នៃការជជែកពិភាក្សាគ្នា ។

តាមការសិក្សាស្រាវជ្រាវឯករាជ្យមួយលើការបោះឆ្នោត បង្ហាញថារាល់ដំណើរការនៃការរៀបចំបោះឆ្នោតពីដំណាក់កាលមួយទៅមួយ មានការរីកចំរើនជាបន្តបន្ទាប់ ។ ខប់សែល ជាយន្តការមួយសំខាន់ ដែលបានចូលរួមចំណែកដល់ដំណើរការរៀបចំការបោះឆ្នោតដែលតម្លាភាព យុត្តិធម៌ ដែលយន្តការនេះ ជំរុញឱ្យមានការពិភាក្សាពីបញ្ហានានាជុំវិញការបោះឆ្នោត ដោយបើកចំហ ស្មោះត្រង់ជា មួយគ្នា ។ កិច្ចការសំខាន់មួយរបស់ ខប់សែល គឺជាប់ទាក់ទិននឹងគ្រប់ភាគីសំខាន់នានាក្នុងការបោះឆ្នោត ក្នុងនោះមានជាប់ទាក់ទងជាមួយក្រសួងមហាផ្ទៃ គជប ដែលបានគាំទ្រដល់ វិទ្យាស្ថាន CDRI និងពីសំណាក់អាជ្ញាធរខេត្ត គជបខ ។ លោកសូមអរគុណដល់ ឯកឧត្តម ឆាយ សារ៉េត អភិបាលខេត្តពោធិ៍សាត់ ដែលបានអនុញ្ញាតឱ្យ វិទ្យាស្ថាន CDRI រៀបចំកិច្ចប្រជុំនេះឡើង លោក ផាន់ វណ្ណសិទ្ធិ ប្រធាន គជបខ ដែលលោកនឹងបង្ហាញជូនលោក លោកស្រីអំពីស្ថានភាពនៃការរៀបចំការបោះឆ្នោតនៅក្នុងខេត្តពោធិ៍សាត់កន្លងមក ។ ទន្ទឹមនេះ

ក៏មានការចូលរួម និងគាំទ្រពីតំណាងគណបក្សនយោបាយ សង្គមស៊ីវិល អាជ្ញាធរមូលដ្ឋាន ពិសេសពីអាជ្ញាធរថ្នាក់ស្រុក សមាជិកក្រុមប្រឹក្សាឃុំ ។ គោលបំណងសំខាន់របស់យន្តការនេះ គឺការបង្កបរិយាកាសឱ្យមានការជួបជុំគ្នា និង ជជែកវែកញែកលើបញ្ហានានា ដោយស្មោះត្រង់ បើកចំហ ដែលនេះជាដំណើរការឆ្ពោះទៅរកការកសាងលទ្ធិប្រជាធិបតេយ្យ ។ រាល់កិច្ចពិភាក្សានានា នៅថ្នាក់ខេត្ត ខប់សែល នឹងយកចំណុចសំខាន់ៗដែលលោក លោកស្រីបានលើកឡើង ដាក់ជូនក្នុងអង្គប្រជុំនៅថ្នាក់ជាតិ ដើម្បីធ្វើការពិចារណាបន្តទៀត ។ ជោគជ័យនៅក្នុងកិច្ចប្រជុំពេលនេះ អាស្រ័យលើការចូលរួមមតិរបស់លោក លោស្រី ដែលពាក់ព័ន្ធនឹងការបារម្ភ បញ្ហាប្រឈម និងការលំបាកនានានៅតាមមូលដ្ឋាន ។

## ២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឪក សេរី សោភគ្គី ទីប្រឹក្សា និងជាអ្នកសំរបសំរួល យន្តការខប់សែល នៃវិទ្យាស្ថាន CDRI

លោក **ឪក សេរី សោភគ្គី** សូមអរគុណលោក ឡារី ស្ត្រេន្ទ ដែលទោះជារវល់យ៉ាងណា ក៏តែងឆ្លៀតពេលចូលរួមក្នុងកម្មវិធីខប់សែល នៅខេត្តឯទៀតៗ ដែលបានធ្វើកន្លងមក ដូចជានៅខេត្តមណ្ឌលគីរី រតនគីរី ស្ទឹងត្រែង ទោះជាស្ថានភាពនៃការធ្វើដំណើរលំបាកយ៉ាងណា ក៏នៅតែចូលរួមជាមួយក្រុមការងារ ខប់សែល ដែរ ។

លោកបានជំរាបជូនអង្គប្រជុំពីប្រវត្តិ ខប់សែល ដោយសង្ខេបថា នៅពេលលោក តស៊ូនៅជាយដែនជាមួយឯកឧត្តម ស៊ឹន សាន អស់រយៈពេល ១១ឆ្នាំ លោកបានឃើញពីអ្វីដែលកើតឡើងនៅជំនាន់ខ្មែរក្រហម ពលរដ្ឋយើងទទួលរងទុក្ខវេទនា ត្រូវគេធ្វើបាបនៅជំរំតាមជាយដែន តាមអំពើចិត្ត ។ នៅពេលធ្វើមាតុភូមិនិវត្តន៍ចូលស្រុកវិញ ក្នុងស្មារតីផ្សះផ្សា បង្រួបបង្រួមជាតិ លោកបានធ្វើការជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យរបស់ឯកត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ១៩៩៣-១៩៩៨ ។ នៅពេលឃើញ ការលំបាកវេទនា ការស្លាប់ ការដែលប្រជាពលរដ្ឋត្រូវគេធ្វើបាប ហើយវិនាស ហិនហោចដោយសារសង្គ្រាម អស់រយៈពេលប្រហែល ២៨ឆ្នាំ លោកក៏ចេះតែគិតថា ធ្វើយ៉ាងណាដើម្បីឱ្យប្រទេសកម្ពុជា ដែលបានកសាងមកដោយ លំបាកក្នុងរយៈកាលកន្លងមកនេះ ដូចជាមានផ្លូវថ្នល់ ទឹក ភ្លើង សាលារៀន មន្ទីរពេទ្យ ហើយអាចជួបនិយាយពិភាក្សាគ្នាបាន ធ្វើដំណើរទៅណាមកណា ក៏បាន ដែលកាលពីមុនពេលធ្វើ ដំណើរពីភ្នំពេញទៅបាត់ដំបង ត្រូវដេកផ្លូវមួយយប់ ។ តែឥឡូវចំណាយតែ ៣ ម៉ោងប៉ុណ្ណោះ ។ គ្រោះធម្មជាតិ ទឹកជំនន់ បានបំផ្លាញហេដ្ឋា រចនាសម្ព័ន្ធនានា ដូចជា នៅបាត់ដំបង ក្រុងព្រះសីហនុដាច់ផ្លូវ និងខកខានមិនបានទៅរៀបចំកិច្ចប្រជុំបែបនេះនៅខេត្តកោះកុង កាលពីខែមុន ដូច្នេះទើបបានជំរាបទៅឯកឧត្តមអភិបាលខេត្ត ដើម្បីដកថយមកភ្នំពេញវិញ ។ ទោះខំកសាងយ៉ាងណា គ្រោះធម្មជាតិបានបំផ្លាញច្រើនណាស់ ចុះបើយើងឈ្លោះគ្នាទៀត បើនិយាយស្តាប់គ្នាមិនបាន និងមានវិបត្តិថែមទៀត តើយើងនឹងធ្លាក់ចុះក្នុងដំណើរការកសាងប្រទេសយើងយ៉ាងណា?

នៅពេលកំពុងធ្វើការជាមួយឯកត្តម ស ខេង លោកបានចាប់ផ្តើមរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៤ ដើម្បីត្រៀមរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នេះ តែការងារនេះចេះតែបន្តដល់ឆ្នាំ២០០២ ទើបអាចរៀបចំបាន ។ ដូចយើងបានដឹងហើយ កាលពីបោះឆ្នោតឆ្នាំ១៩៩៨ យើងជួបប្រទះអំពើហិង្សាច្រើនណាស់ រហូតដល់មុខមាត់ និងកេរ្តិ៍ឈ្មោះប្រទេសយើង មានស្ថានភាពអាក្រក់បង្ហាញនៅក្នុងទូរទស្សន៍ CNN ឱ្យសាកលលោក ឃើញរូបភាពអំពើហិង្សាច្រើនណាស់ ។ នៅពេលនោះ វិទ្យាស្ថាន CDRI (ក្រោយពីឈប់ធ្វើការងារជាមួយរាជរដ្ឋាភិបាល) ដែលបានចូលធ្វើការ ក្នុងឋានៈជាអ្នកសំរបសំរួល កម្មវិធីសន្តិភាព និងអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ លោកបានសុំឱ្យអ្នកជំនាញការម្នាក់រៀបចំស្រាវជ្រាវថា តើហេតុអ្វីបានជាក្នុងឆ្នាំ១៩៩៨ យើងមានទំនាស់ខ្លាំងរហូតដល់ខូចមុខមាត់ព្រះរាជាណាចក្រកម្ពុជា? នៅពេលនោះលោកចុះទៅសិក្សាជាមួយព្រះគ្រូចៅ អធិការ នៅតាមភូមិ ឃុំ និងអង្គការ ជាតិ អន្តរជាតិ

សង្គមស៊ីវិល រាជរដ្ឋាភិបាល និងបានទទួលការគាំទ្រពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី យើងរកឃើញ នូវយន្តការបង្កាទំនាស់មួយដែលហៅកាត់ថា ឧប់សែល ពីឆ្នាំ១៩៩៩ ដល់ ២០០៣ ដើម្បីបំរើដល់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២ ។ ដូចលោក ឡារី ស្រ្តេន្ទ បានលើកឡើងអញ្ចឹង ឧប់សែល ធ្វើការជួបប្រជុំរៀងរាល់ខែ ហើយពាក់ព័ន្ធនឹងតួអង្គសំខាន់ទាំងទាំងអស់ ។ នៅពេលទទួលបានជោគជ័យ និងបានជួយដល់ គជប ក្នុងការរៀបចំការបោះឆ្នោត នៅឆ្នាំ២០០២ បានច្រើន ហើយអង្គប្រជុំបានសំរេចបន្តកម្មវិធីនេះ ដើម្បីបំរើដល់ការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០០៣ ។ ដល់ធ្វើបានជោគជ័យអញ្ចឹងទៅ លោកគិតថា ចប់ហើយនៅឆ្នាំ ២០០៣ នេះ ក៏ប៉ុន្តែដល់ពេលដែលយើងរៀបចំការបោះឆ្នោត ២០០៧-២០០៨ អង្គការសហប្រជាជាតិ ជាពិសេស លោក Douglas Gardner ដែលទើបតែមកថ្មី គាត់បានមើលសេចក្តីរាយការណ៍ហ្នឹង គាត់បានអាននៅញ៉ូវយ៉ក ហើយបានមកភ្នំពេញ គាត់ថាយន្តការនេះល្អណាស់ ហើយក៏បានមក ជួប លោក Larry Strange និងរូបលោក សូមឱ្យធ្វើបន្តទៅទៀត ព្រោះយន្តការបែបនេះមិនមានទេនៅក្នុងសកលលោក ជាពិសេស នៅប្រទេសដែលចេញពីសង្គ្រាមយូរអង្វែង ហើយចេះបង្កើតយន្តការជជែកពិភាក្សាគ្នាដោយខ្លួនឯងអញ្ចឹងមិនមានទេ ព្រោះថាវាជា មេរៀន នៃការរៀនសូត្រ មិនមែនគ្រាន់តែជាមេរៀនសម្រាប់ប្រទេសកម្ពុជាទេ គឺជាមេរៀនសម្រាប់ប្រទេសថ្មីៗ ដែលទើបតែចេញពីសង្គ្រាម ដូចយើងដែរ ។ ម្យ៉ាងវិញទៀត តាំងពី ឧប់សែល ដំណាក់កាលលើកទី ១ មក រាល់អង្គប្រជុំសំរេចថា ដើម្បីឱ្យមានតម្លាភាព ត្រូវថត សម្លេងវាគ្មិនដែលបានបញ្ចេញមតិទាំងអស់ ហើយលេខាធិការដ្ឋាន ឧប់សែល និងធ្វើកំណត់ហេតុតាមនោះដែរ ។ ដូច្នេះ វប្បធម៌នៃការពិភាក្សាគ្នានេះ ត្រូវបានប្រព្រឹត្តទៅដោយការទទួលខុសត្រូវចំពោះមុខអ្នកអាននានា ។ ទំនៀមទំលាប់នេះ ចេះតែមានជាបន្តបន្ទាប់ រហូតមកដល់ពេលនេះ ។ កាលពី ឧប់សែល ដំណាក់កាលលើកទី ១ គឺមានតែត្រឹមថ្នាក់ជាតិប៉ុណ្ណោះ តែ ឧប់សែល នៅដំណាក់កាលទី ២ នេះ លោកប្រធាន UNDP បានមានប្រសាសន៍ថា ដោយសារវាជាយន្តការដែលខ្មែរបង្កើតឡើងដោយខ្លួនឯង លោកបានគូសវាសវាឡើងដោយមិនសួរអ្នកណានៅខាងក្រៅទេ ដែលនេះជាមោទនភាពរបស់ខ្មែរយើង ។ ដូច្នេះការជជែកពិភាក្សាគ្នាដើម្បីបង្កាទំនាស់ ដើម្បីរកសន្តិភាពក្នុងសង្គម ដែលអនុញ្ញាតឱ្យសេដ្ឋកិច្ចងើបឡើងពិបាកណាស់ យើងអាចបញ្ចប់សង្គ្រាមបាន តែយើងនៅច្បាំង នឹងការអភិវឌ្ឍន៍ ហើយឱ្យម្នាក់ៗស្តាប់យល់គ្នាបានពិបាកណាស់ ។ ដូច្នេះយើងបានពិចារណាបន្តទៀត អំពីទំនាស់នានាដែលកើតឡើង ។ បន្ទាប់ពីបានចុះទៅភូមិ ឃុំ ជាច្រើន ឃើញថាទំនាស់ភាគច្រើនកើតមានឡើងនៅថ្នាក់មូលដ្ឋាន ព្រោះថាទំនាស់នៅថ្នាក់ជាតិ បើមាន ក៏តិចតួចដែរ ព្រោះមេៗគណបក្សនយោបាយ ឈ្លោះជាៗ គឺជារឿងរបស់មេ ។ តែបើការទាស់គ្នានៅមូលដ្ឋាន មិនដូច្នេះទេ តែកាលណាឈ្លោះគ្នា តែងយកជាឈ្លោះមែនទែន ។ ហេតុនេះបានជា យើងឱ្យតំលៃលើ ឧប់សែលប្រ៊ម នៅតាមខេត្តខ្លាំងជាង ដោយអញ្ជើញក្រុមប្រឹក្សាឃុំ មកចូលរួម ដែលខ្លះជាមេភូមិ តំណាងគណបក្សនយោបាយនានា តំណាងអង្គការសង្គមស៊ីវិល ។ ឆ្លៀតឱកាសនោះ លោកបានថ្លែងកោតសរសើរ និងគោរពដល់អង្គការសង្គមស៊ីវិលទាំងអស់នៅកម្ពុជាដែលមានតាំងពីឆ្នាំ១៩៩៣ បានជួយការងារច្រើនផ្នែកណាស់ទាំងការអភិវឌ្ឍន៍ និងអ្វីៗផ្សេងទៀត ។

យន្តការនេះបានឱ្យតំលៃលើគ្រប់ដំណាក់កាលនៃការបោះឆ្នោតទាំងអស់ ក្នុងគោលដៅបី ទី១ ចង់ធ្វើយ៉ាងណាឱ្យពលរដ្ឋដែលមានអាយុ១៨ឆ្នាំ គ្រប់អាយុបោះឆ្នោត ចុះឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតបានទាំងអស់គ្នា ។ យើងដឹងហើយថា នេះជាការងារពិបាក ដោយពលរដ្ឋយើងនៅភាគច្រើនតែងបានប្តូរឈ្មោះ ។ ហេតុនេះហើយបានជា ឧប់សែលប្រ៊ម នៅខេត្តនានាស្នើកុំឱ្យធ្វើបែបនេះ ។ យើងចង់ឱ្យដំណើរការចុះឈ្មោះ ក្លាយជាទំលាប់ដូចយើងញ៉ាំបាយ ស្លៀកពាក់ដែរ ទោះជាតឡូវធ្វើមិនទាន់បានមែន ខាង គជប គិតថា ២០ថ្ងៃ នៅខែតុលាធ្វើមិនគ្រប់ទេ ទើបឱ្យមានការចុះឈ្មោះត្រៀមរយៈពេល៩ខែ ពីមករា ដល់ កញ្ញា ។ ដោយសារមានប្រតិភូកម្មអំណាចទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសស្មៀន ដែលធ្វើការមិនបានគ្រប់២០ថ្ងៃទេ ដោយរវល់ទៅបណ្តុះបណ្តាលនៅក្រសួងមហាផ្ទៃ ខាងសង្គមស៊ីវិល សីលា SPA, PLAU និងកម្មវិធីនានាទៀត ។ ដូចនេះការចុះឈ្មោះឆ្នាំនេះ យើងបានពិភាក្សាជាមួយស្ថាប័នទាំងនោះ សុំកុំ

ឱ្យរំខានដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្មៀន ក្នុងការចុះឈ្មោះបោះឆ្នោតឱ្យបានប្រាកដ ២០ថ្ងៃ ដោយបញ្ជាសកម្មវិធីនានាឱ្យអស់ ។ ចំណុចគោលដៅ ទី ២ គឺយើងចង់ឱ្យអត្តសញ្ញាណប័ណ្ណ បានដល់ដៃពលរដ្ឋទាំងអស់គ្នា ។ នៅភ្នំពេញយើងធ្វើការប្រជុំពីរឿងនេះបីខែជាប់ៗគ្នា ដោយបានមើលកំណត់ហេតុ ទើប គជប និងក្រសួងមហាផ្ទៃ បានបើកយុទ្ធនាការផ្តល់អត្តសញ្ញាណប័ណ្ណ ឱ្យបានដល់ពលរដ្ឋ ១.៩០០.០០០នាក់ ដែលមិនទាន់បានទទួល ហើយត្រូវតែបានទទួលគ្រប់គ្នារហូតចុងឆ្នាំ២០០៦ ។ ទី ៣ ចង់ឱ្យការជជែកដែលមានលោក លោកស្រីខាង រាជអាវុធហត្ថ ស្នងការ អង្គការសង្គមស៊ីវិល ដោយចង់ឱ្យយន្តការនៃការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលមិនមែនមានតែបោះឆ្នោតសាកលទេ ដូចឃើញស្រាប់ហើយ ការបោះឆ្នោតអសាកលខែមករា ឆ្នាំ២០០៦ បោះឆ្នោតព្រឹទ្ធសភា ហើយនៅអនាគតនឹងមានការបោះឆ្នោតអសាកលក្រុមប្រឹក្សាខេត្ត និងស្រុក ដែលច្បាប់រិមជ្ឈការ និងសហវិមជ្ឈការកំពុងតែរៀបចំ ប្រហែលនឹងអនុម័តនៅចុងឆ្នាំនេះ ។ ចង់ឱ្យយន្តការបោះឆ្នោតក្លាយជាទំលាប់ប្រជាធិបតេយ្យមួយរបស់ពលរដ្ឋខ្មែរ ប្រកបដោយសុវត្ថិភាព រឿងហិង្សាអាចកើតឡើងគ្រប់ពេលទាំងអស់ តែចរឹត អាកប្បកិរិយា ឥរិយាបថរបស់ មនុស្សជាអ្នកគ្រប់គ្រងហិង្សានោះដែលជាការសំខាន់ ។ អ្វីដែលអាចធ្វើទៅបានទាល់តែមានវប្បធម៌ជជែកពិភាក្សា ព្រោះខ្មែរយើងទំលាប់ នៅទល់មុខគ្នា សើច ញញឹមគួរសមដាក់គ្នា តែនៅក្រោយខ្នង ១០០៧ ។ បញ្ហាដែលកើតឡើងទាំងអំបាលមាណ យកមកដាក់លើតុ ហើយនិយាយដោយស្មោះត្រង់ ពេលនោះយើងអាចមិនឯកភាពជាមួយគ្នាមែន តែយើងនឹងចាប់ផ្តើមយល់ថា ហេតុអ្វីបានជាគេមានគំនិតខុសពីយើង ចាប់ផ្តើមការគោរពភាពខុសគ្នានឹងនាំឱ្យយើងគ្រប់គ្រង និងបង្ការទំនាស់បាន ។ នៅពេលនោះយន្តការបោះឆ្នោត ដែលជាយន្តការសំខាន់ណាស់ក្នុងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ នឹងធ្វើឱ្យសង្គមកម្ពុជាក្លាយជាសង្គមមួយដែលមានអារ្យធម៌ វប្បធម៌រុងរឿងដូចជំនាន់ដើមឡើងវិញ នៅពេលនោះដែលសង្គមយើង លែងត្រលប់ទៅរកយុគខ្មៅងងឹតវិញបាន ហើយយើងនឹងទុកមរតកនេះដល់ជនានុជនជំនាន់ក្រោយ កុំឱ្យអភ័ពដូចជំនាន់យើងទៀត ។ ទាំងអស់នេះ អាចសំរេចទៅបាន អាស្រ័យលើលោក លោកស្រីទាំងអស់ដែលមានវត្តមាននៅទីនេះ យើងមានក្តីសោមនស្សរីករាយណាស់ ដែលអាចធ្វើរឿងនេះបាននៅ បន្ទាយមានជ័យ ក្រុងប៉ៃលិន បាត់ដំបង និងខេត្តនានាដែលបានធ្វើរួចហើយ ឃើញមានការចូលរួមយ៉ាងសកម្ម ។ សង្ឃឹមថា លោក លោកស្រី នឹងមាន ប្រសាសន៍ឱ្យអស់ពីចិត្ត រឿងក្តៅគគុក តែចេះប្រើពាក្យសំដី អាកប្បកិរិយា ឱ្យស្ថិតក្នុងសភាពថ្លៃថ្នូរ គោរពគ្នាទៅវិញទៅមក ។

## ៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក ផាន់ វណ្ណសិទ្ធិ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តពោធិ៍សាត់

ជំនួសមុខឱ្យ គជបខ លោកមានកិត្តិយសណាស់សូមជំរាបជូនអង្គប្រជុំដោយសង្ខេបជុំវិញការងារបោះឆ្នោតទូទៅនៅខេត្តពោធិ៍សាត់នារយៈកាលកន្លងមក ហើយបានស្វាគមន៍ និងគោរពដល់ភ្ញៀវកិត្តិយសទាំងអស់ដែលមានវត្តមានក្នុងអង្គប្រជុំ ខប់សែលប្រ៉ម ។ លោក សង្ឃឹមថា ក្រោយពីលោកបានធ្វើរបាយការណ៍ដោយសង្ខេបនេះចប់ លោក លោកស្រី នឹងលើកជាបញ្ហានានាឡើង ដូចជា ចម្ងល់ និងអនុសាសន៍ សំណូមពរទាក់ទងនឹងយន្តការផ្សេងៗ ជុំវិញការងារបោះឆ្នោត ហើយសង្ឃឹមថា លោក លោកស្រីនឹងបង្ហាញបញ្ហានានាឱ្យអស់ និងដោយស្មោះត្រង់ នៅចំពោះមុខគ្នា ជជែក វែកញែកជាមួយគ្នា ដែលវេទិកានេះ ជាថ្នាលបណ្តុះវប្បធម៌ថ្មី ដើម្បីបញ្ជាសបាននូវទំនាស់ផ្សេងៗ ដែលអាចឈានដល់អំពើហិង្សានានា ។

ការងារបោះឆ្នោតតែងទាមទារកត្តាសំខាន់បី ដែលយើងបានប្រព្រឹត្តទៅ ៥ លើករួចហើយ គឺនៅឆ្នាំ១៩៩៣ រៀបចំដោយអ៊ុនតាក់ ១៩៩៨ រៀបចំដំបូងដោយកំលាំងរបស់កម្ពុជាយើង ហើយការបោះឆ្នោតឆ្នាំ២០០២, ២០០៣ ក៏យើងរៀបចំដែរ និងថ្មីៗនេះយើងបានរៀបចំការបោះឆ្នោត សមាជិកព្រឹទ្ធសភានៅឆ្នាំ២០០៦ នេះក្នុងលក្ខណៈអសាកល ។ ក្នុងការបោះឆ្នោតទាំង ៥ លើកនេះ យើង

ទាំងអស់គ្នាបានឃើញហេតុការណ៍ផ្សេងៗ ដែលដំណោះស្រាយមានជាបន្តបន្ទាប់ ។ កត្តាសំខាន់ទាំងបី សំរាប់ការងារបោះឆ្នោតគឺទី១ ច្បាប់ ដែលបានឆ្លងកាត់តាំងពីការធ្វើសេចក្តីព្រាងពីក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី រដ្ឋសភា ព្រឹទ្ធសភា និងឡាយព្រះហស្ថលេខាពីព្រះមហាក្សត្រ គឺត្រូវមានច្បាប់មួយជាគោលដើម្បីដំណើរការ ។ ទី២ គឺការរៀបចំអាជ្ញាធររៀបចំការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់គឺ គជប មន្ត្រីលេខាធិការដ្ឋានខេត្ត ឃុំ បំរើការងាររហូតដល់ការិយាល័យបោះឆ្នោត ។ កត្តាទី ៣ ដែលសំខាន់បំផុតនោះគឺ ពលរដ្ឋដែលគ្រប់អាយុ១៨ឆ្នាំ ឡើងចូលរួមបំពេញកាតព្វកិច្ច ក្នុងការងារចុះឈ្មោះ និងការងារផ្សេងៗទៀត ដែលបំពេញបែបបទសំរាប់បំរើការបោះឆ្នោត ។

ចំពោះកត្តាច្បាប់ដែលកើតមានជាបញ្ហាកន្លងមក ដោយសារយើងមិនទាន់យល់គ្នាទៅវិញទៅមក ដែលច្បាប់នោះមិនមែនត្រូវរៀន តែមន្ត្រីចំណុះ គជប ទេ តែបានបើកទូលាយទៅដល់គណបក្សនយោបាយ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ ដើម្បីឱ្យយល់បានជ្រួតជ្រាបពីការងារនេះទាំងអស់គ្នា ។ ការងារដែលបានអនុវត្តកន្លងមក ច្រើនប៉ះទង្គិចគ្នាលើផ្នែកច្បាប់នេះជាចំបងគេ ដែលក្នុងនោះទាក់ទិនដល់ គជប ខ្លួនឯង ដែលគណបក្សនយោបាយចោទឡើង និងពលរដ្ឋ ច្រើនប៉ះពាល់នឹងផ្លូវច្បាប់នេះ ។ នៅពេលមានច្បាប់នឹងមាននីតិវិធី បទបញ្ជា ក្រមសីលធម៌ជាច្រើនទៀត និង តារាងប្រតិទិនការងារសំរាប់អនុវត្ត ដូចជាក្រមសីលធម៌សំរាប់កងកម្លាំងប្រដាប់អាវុធដើម្បីការពារសន្តិសុខ ក្រមសីលធម៌ចំពោះគណបក្សនយោបាយ ក្រមសីលធម៌ចំពោះអង្គការសង្គមស៊ីវិល ក្រមសីលធម៌សំរាប់មន្ត្រីរៀបចំបោះឆ្នោត ដើម្បីឱ្យយើងទទួលស្គាល់មុខសញ្ញា តួនាទី ជៀសវាងការរំលោភបំពានគ្នាទៅវិញទៅមក ។ បើទាំងអស់គ្នាយល់ពីការងារច្បាប់ទាំងអស់នេះបាន នោះការងារនេះនឹងដើរទៅមុខរលូនល្អហើយ ។ ជាមួយនេះ យើងមានយន្តការមួយទៀត គឺឧប់សែល បានប្រមូលផ្តុំមន្ត្រី និងអ្នកជាប់ពាក់ព័ន្ធនឹងការងារបោះឆ្នោះ មកនិយាយដោះស្រាយបញ្ហាទល់មុខគ្នា ដើម្បីឱ្យបានដឹងថាតើដំណើរការយើងបានដល់កំរិតណាហើយ មានបញ្ហាអ្វីខ្លះ ដោយជូនដំណឹងគ្នាទៅវិញទៅមក ហើយមានបញ្ហាខ្វះចន្លោះ ក្នុងប្រការណាមួយ នឹងលើកយកវាមកជជែកគ្នាជាលក្ខណៈសាមញ្ញ ឬវិសាមញ្ញទៅតាមដំណាក់កាល ។

ទោះជាមានការរៀបចំអាជ្ញាធរនានាទៅតាមលំដាប់ និងបានអនុវត្តតាមនីតិវិធី ព្រមទាំងការជ្រើសរើសមន្ត្រីប្រើក៏ដោយ ក៏នៅតែជៀសមិនផុតពីការរិះគន់ និងអនុសាសន៍នានាថែមទៀតក្នុងន័យស្ថាបនា និងរិះគន់ដែរ និងបានធ្វើឱ្យថយបញ្ហាអវិជ្ជមាននានា និងឱ្យទាំងអស់គ្នាអាចទុកចិត្ត ហើយធ្វើការជាមួយគ្នាកើត ។ ចំពោះកត្តាមហាជនចូលរួមក្នុងការបោះឆ្នោត ចំពោះវចនាសម្ព័ន្ធនានា គឺអនុវត្តតាមការចាត់តាំង និងមានកន្លែងអង្គុយ និយាយគ្នា តែចំពោះពលរដ្ឋរស់នៅក្នុងភូមិ សហគមន៍ គ្មានការិយាល័យទេ គឺរស់នៅក្នុងលក្ខណៈជាគ្រួសារ ដូច្នេះការអប់រំពីអាជ្ញាធរដែនដី អង្គការ សង្គមស៊ីវិល គឺបានធ្វើដោយដុំ ចន្លោះ ។ ពលរដ្ឋទទួលការអប់រំដោយគ្មានកន្លែង មិនមានការប្រមូលផ្តុំ មិនមានសាលារៀនទេ ហេតុនេះការផ្សព្វផ្សាយតាមខិតប័ណ្ណ បដា រូបភាព ឧគ្ឃោសនស័ព្ទ វិទ្យុ ទូរទស្សន៍ និងការចូលរួមប្រជុំផ្សេងៗតាមការចាត់ចែង ដូច្នេះកន្លែងអប់រំរបស់ពួកគាត់ គឺស្ថិតនៅក្នុងបរិយាកាស ។ ទោះទទួលពតិមានពីមន្ត្រីនានាហើយក៏ដោយ ក៏ពួកគាត់នៅគិតដល់ជីវភាពរស់នៅ សុខភាព ក្នុងក្រុមគ្រួសារ ជាធំដែរ ។ នាឆ្នាំកន្លងមក នៅពេលបោះឆ្នោតនីមួយៗ ប្រជាពលរដ្ឋយើងបានកើនឡើងទាំងអ្នកចុះឈ្មោះបោះឆ្នោត តែសមាមាត្រជាភាគរយនៃអ្នកចូលរួមបោះឆ្នោត មិនទាន់ធ្លាក់ក្រោម ៨០% ទេ នៅក្នុងខេត្តពោធិ៍សាត់ ។ នៅឆ្នាំ១៩៩៣ ចុះឈ្មោះបាន ១០០% ពេលទៅបោះឆ្នោតបាន ៩៣% នៅឆ្នាំ១៩៩៨ ចុះឈ្មោះបាន ១០០% ទៅបោះឆ្នោតបាន ៩៧% នៅឆ្នាំ២០០២ ចុះឈ្មោះបាន ៩១% និងនៅឆ្នាំ២០០៣ ចុះឈ្មោះបានប្រហែល ៩២% ។ តួលេខបង្ហាញថា ការចុះឈ្មោះបោះឆ្នោតធ្លាក់ចុះបន្តិចបន្តួច នេះក៏បានបង្ហាញពីការចូលរួមរបស់ពលរដ្ឋ គឺនៅមានលំនឹងគួរឱ្យទុកចិត្តបាន ហើយបញ្ហានៅចំពោះមុខ ដែលបញ្ហាមិនសូវចោទឡើងរវាងគណបក្សនយោបាយ និងអង្គការចាត់តាំងទេ តែវាចោទក្នុងចង្កោមគណបក្សនយោបាយក្នុងចំណោមមហាជន នៅក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ដែលរាល់ឆ្នាំ គជប បានកំណត់បែបផែន នីតិវិធី

ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ និងស្មៀន ចាប់តាំងពីឆ្នាំ២០០៤ មក ដែលក្នុងមួយឆ្នាំនេះ ក្រុមប្រឹក្សាឃុំ និងស្មៀន មានរយៈពេលតែ ២០ថ្ងៃ ដើម្បីធ្វើការពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះពលរដ្ឋ ដែលគ្រប់អាយុ និងអ្នកដែលមិនធ្លាប់បានចុះឈ្មោះបោះឆ្នោត ។ ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងឆ្នាំ២០០៤-០៥ កន្លងមកនេះ មិនទាន់បានល្អគួរជាទីពេញចិត្តទេ តែបានប្រព្រឹត្តទៅតាមនីតិវិធី ដោយសារពលរដ្ឋមិនសូវទទួលបានការយល់ដឹងអំពីដំណាក់កាលចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះ ការផ្សព្វផ្សាយមិនបានជ្រួតជ្រាបដល់ ពលរដ្ឋកន្លែងខ្លះមានវិទ្យុ កន្លែងខ្លះមានទូរទស្សន៍មើលមិនឃើញ ។ គជប ក៏បានបង្កើនការផ្សព្វផ្សាយនេះដែរ ដូចជា ការចងបដា ចែកខិតប័ណ្ណ ចាក់មីក្រូចល័ត ឃោសនានៅតាមវត្តអារាមនាពេលបុណ្យទាន និងបានណែនាំក្រុមប្រឹក្សាឃុំ ជំរាបពលរដ្ឋអំពី ប្រតិទិនការងាររបស់ក្រុមប្រឹក្សាឃុំនេះដែរ ។ ការចុះឈ្មោះនេះ គឺយើងបានធ្វើជារៀងរាល់ឆ្នាំ តែឆ្នាំ២០០៥ធ្វើមិនបានដូចឆ្នាំនេះទេ ដោយបាន ធ្វើការសំអាតបញ្ជីឈ្មោះអ្នកបោះឆ្នោតជាប្រចាំ ដោយលុបចេញអ្នកស្លាប់ ផ្លាស់ចេញ ទណ្ឌិត អ្នកមានឈ្មោះស្ទួន និងចុះថែមនូវអ្នកដែលទើបគ្រប់អាយុថ្មី អ្នកមិនធ្លាប់ចុះឈ្មោះបោះឆ្នោត ដូចជា ព្រះសង្ឃ ដូនជី ប្រជាពលរដ្ឋដែលផ្លាស់ចូល និងចល័តកន្លែងច្រើនដង ។

នៅឆ្នាំ២០០៦ នេះ គជប បានបង្កើតយុទ្ធសាស្ត្រថ្មីមួយទៀត ដើម្បីបញ្ជៀសការមិនបានទទួលពតិមាន បញ្ជៀសការចោទប្រកាន់លើអាជ្ញាធរដែនដី បញ្ជៀសការចោទប្រកាន់លើ គណបក្សនយោបាយ ដោយប្រើប្រាស់ប័ណ្ណពតិមានអ្នកបោះឆ្នោត ដែលយើងធ្វើការចែកជូនពលរដ្ឋបាន ១៧ថ្ងៃ ហើយ ក្នុងនោះមានទិន្នន័យនានា ដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីកន្លែងកំណើត ទីលំនៅ លេខរៀងក្នុងបញ្ជីបោះឆ្នោត លេខរៀងនិងទីតាំង ការិយាល័យបោះឆ្នោត ។ អ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត២០០៥ នឹងបានទទួលទាំងអស់គ្នា ។ ចាប់ពីថ្ងៃទី ១ កញ្ញា ទៅ ពលរដ្ឋនឹងយកប័ណ្ណ នេះទៅផ្ទៀងផ្ទាត់ ជាមួយនឹងអត្តសញ្ញាណណាមួយដែលអាចយកទៅប្រើប្រាស់សំរាប់ការបោះឆ្នោតបាន ។ បញ្ជីឆ្នាំ២០០៦ នេះ នឹងប្រើប្រាស់សំរាប់ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃ ០១ មេសា ២០០៧ ។ ចំពោះយុវវ័យដែលមានឆ្នាំកំណើតនៅឆ្នាំ១៩៨៨ នឹងទទួលបានអត្តសញ្ញាណប័ណ្ណ តែដើម្បីឱ្យមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបាន ( អ្នកដែលមានអាយុ ១៨ឆ្នាំ គិតត្រឹមថ្ងៃ ០១ មេសា ២០០៧) គឺត្រូវទៅធ្វើទំរង់ ១០១៨ ហើយប័ណ្ណបោះឆ្នោត ១៩៩៣ ១៩៩៨ ២០០៣ លែងយកមកប្រើសំរាប់ការបោះឆ្នោតទៀតហើយ ដូចនេះ ពលរដ្ឋម្នាក់ៗត្រូវមាន អត្តសញ្ញាណប័ណ្ណ ។ ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះក្នុងឆ្នាំ២០០៦ វាជាភារកិច្ចរបស់ពលរដ្ឋ ហើយវាក៏ជាការងារសំខាន់សំរាប់គណបក្ស នយោបាយនានា អាជ្ញាធរដែនដីក៏ត្រូវសកម្មចូលរួមក្នុងការជំរុញសមាជិក និងបំផុសពលរដ្ឋ ដើម្បីរៀបចំបំពេញ ឱ្យពលរដ្ឋមានអត្តសញ្ញាណ ដើម្បីសំអាង និងអាចយកទៅបោះឆ្នោតបាន ដូចជា ការចេញទំរង់ ១០១៨ ទៅចូលរួមធ្វើអត្តសញ្ញាណប័ណ្ណ ចុះបញ្ជីអត្រានុកូលដ្ឋាន ដែលអង្គការ គំរោងធ្វើនៅក្នុងខេត្តនេះ កំពុងជំរុញការងារនេះ ។ បើគ្មានអត្តសញ្ញាណនានាទេ ពលរដ្ឋមិនអាចទៅបោះឆ្នោតបានទេ ដូចនេះហើយបានជាបញ្ជីបោះឆ្នោតក្នុងឆ្នាំកន្លងមក ក៏មិនទាន់សុក្រឹតដែរ ដោយសារពលរដ្ឋចេះតែដូរឈ្មោះតាមការនឹកឃើញ ។ មួយចំណែកទៀត ការចុះបញ្ជីអ្នកបោះឆ្នោត យើងមានពេលវេលា ចែកប័ណ្ណពតិមានអ្នកបោះឆ្នោតពេញមួយខែសីហា ឱកាសពិនិត្យនិងបំពេញសំណុំលិខិតផ្សេងៗនៅខែកញ្ញា ដើម្បីយកប័ណ្ណនេះទៅកែតំរូវ លើបញ្ជីឈ្មោះមួយខែ (កញ្ញា) ដែលត្រូវបានកែតំរូវជារៀងរាល់ឆ្នាំទៅតាមអត្តសញ្ញាណទាំង ១០ ដែលកំណត់ដោយច្បាប់ដែលមានរៀបរាប់នៅក្នុងប័ណ្ណព័តិមាន ។

នៅដំណាក់កាលនៃការចុះឈ្មោះ មិនទាក់ទងបណ្ដឹងអ្វីទេ តែទាក់ទងដល់ពលរដ្ឋ និងអាជ្ញាធរបោះឆ្នោត ដែលចោទដល់ស្មៀនដែលសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើតខុស ដោយមិនបានទៅមើលឈ្មោះខ្លួនឯង និងមិនសូវចាប់អារម្មណ៍នឹងការងារនេះ ស្មៀនបិទឱ្យមើល ៤ថ្ងៃ នៅគ្រប់ការិយាល័យបោះឆ្នោត ដើម្បីឱ្យកែតំរូវ ។ គជប មានពេលវេលាសំរាប់បំពេញឱ្យស្របតាមអត្តសញ្ញាណដែលយកមកប្រើប្រាស់សំរាប់ការងារបោះឆ្នោត ។ នៅពេលឃោសនា ច្រើនជួបប្រទះបញ្ហានានា ព្រោះវាជារដូវរសើប ត្រូវប្រយ័ត្នសកម្មភាពនានារៀងខ្លួន ដែលមានរវាងគណបក្សនិង គណបក្ស ពលរដ្ឋនិងពលរដ្ឋ នៅរដូវនេះមកដល់តែងចាប់ចំណុចគ្នាទៅវិញទៅមក

ជិះម៉ូតូបុកគ្នា ស្រវឹងស្រាកាប់ចាក់គ្នា នៅពេលមានឃាតកម្មកើតឡើងតែងចោទដល់រឿងនយោបាយ ដែលនៅក្នុងវេទិកានេះ យើងបានលើកយកមកពិចារណាទាំងអស់គ្នាថា បើមានហេតុការណ៍អ្វីកើតឡើង តោងសម្លឹងមើល ជុំវិញខ្លួនឱ្យបានគ្រប់ជ្រុង រវាងគណបក្សនយោបាយ អាជ្ញាធរដែនដី កំលាំងមានសមត្ថកិច្ច កុំអាលវាយតំលៃ ត្រូវរួមគ្នាដោះស្រាយ កុំទុកឱ្យ អូសបន្លាយ ។ បើយកពេលឃោសនា មកប្តឹងផ្តល់គ្នា មានពេលឯណាទៅឃោសនា ។ នៅពេលនោះ មានការផ្សព្វផ្សាយនានាច្រើនរូបភាព ដើម្បីឱ្យពលរដ្ឋយល់ពីការបោះឆ្នោត ដោយលើកផ្លាកសំគាល់ផ្សេងៗ ខិតប័ណ្ណ ដែលមានទាំងខាង គជប សង្គមស៊ីវិល គណបក្សនយោបាយនានា ។ មួយវិញទៀត ធ្វើឱ្យមានច្រើននៅតាមទីសាធារណៈ ត្រូវចេះគោរពគ្នា យល់ចិត្តគ្នា នៅពេលលើកបដាផ្សព្វផ្សាយនានា ចូរជៀសវាងការបាំងស្រមោលចោលលើ កុំចោទដាក់គ្នា ត្រូវមានសីលធម៌ក្នុងខ្លួនទាំងអស់គ្នា ។ សូមផ្តល់ដំណឹងដល់អាជ្ញាធរពាក់ព័ន្ធនានា ដូចជា គជប និង អាជ្ញាធរដែនដីជាចំបង ហើយពលរដ្ឋ ដែលនៅក្បែរសូមជួយថែទាំ សូមឱ្យយល់ការងារនេះទាំងអស់គ្នា ។

ដោយសារមានប័ណ្ណព័ត៌មាន លោកជឿថា នៅពេលបោះឆ្នោតអាចបញ្ហាសបញ្ហាបានច្រើន ដែលពីមុនមេភូមិ ឃុំ តែងរងការចោទប្រកាន់ពី គណបក្សនយោបាយ ព្រោះបោះឆ្នោតហើយមិនព្រមទៅផ្ទះ ពេលខ្លះដោយសារយាយចាស់ៗឃាត់ឱ្យជួយមើល ។ គជប ពេលនេះបានបង្កើនមន្ត្រីមួយរូបឱ្យឈរនៅក្រៅការិយាល័យបោះឆ្នោត ដើម្បីជួយសំរួលបញ្ជីឈ្មោះបោះឆ្នោត ដោយមានប័ណ្ណព័ត៌មាន គាត់បង្ហាញជំនួយការម្នាក់នោះជួយរក ។ យើងជឿជាក់ថា ធ្វើបែបនេះលោកមេភូមិលែងរងការចោទប្រកាន់ពីគ្នាទៅវិញ ទៅមកហើយ ។

## ៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការព្រួយបារម្ភទាក់ទងនឹងការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តពោធិ៍សាត់

លោក **ហង្ស ឡុច** អនុប្រធានគណបក្ស ហ៊្វុន  ស៊ិនប៉ិច លោកមានកិត្តិយសណាស់ដែលមានឱកាសលើកឡើងពីបញ្ហានានាទាក់ទិននឹងការបោះឆ្នោតក្នុងពេលកន្លងមក និងក្នុងរយៈពេលខាងមុខ ។ នៅពេលនេះ គជប កំពុងធ្វើការចែកប័ណ្ណព័ត៌មាននៅតាមមូលដ្ឋាននានា ដែលខ្លះរៀបចំចែកបានត្រឹមត្រូវ ហើយខ្លះទៀត មានបញ្ហានានាកើតឡើង ។ នៅក្នុងភូមិមួយចំនួន បានប្រមូលប័ណ្ណនោះឱ្យអាជ្ញាធរដែនដីត្រួតពិនិត្យលើប័ណ្ណដែលត្រូវផ្ទៀងផ្ទាត់ជាមួយនឹងអត្តសញ្ញាណប័ណ្ណ ។ លោកបានជំរាបថា បើអត្តសញ្ញាណប័ណ្ណនោះនៅក្នុងគណបក្ស ក ដែលជា គណបក្សគាត់ នឹងរៀបចំចែកជូនយ៉ាងលឿន តែបើប័ណ្ណនោះក្នុងគណបក្ស ខ គាត់ផ្អឹបប័ណ្ណនោះ ទុកមួយរយៈដោយមិនយកប័ណ្ណនោះទៅធ្វើការផ្ទៀងផ្ទាត់ទេ នៅប្រគល់ដល់ដៃម្ចាស់ប័ណ្ណ (ពលរដ្ឋ) ពេលនោះ ពលរដ្ឋដឹងថា អាជ្ញាធរដែនដីពិនិត្យរួចហើយ ពេលបោះឆ្នោតមានបញ្ហាលើប័ណ្ណនេះ តើនរណាជាអ្នកទទួលខុសត្រូវ? មួយទៀត គជប បានរៀបចំបោះឆ្នោតរើសគណៈកម្មការរួចស្រេចទៅហើយ តែអាជ្ញាធរដែនដីនៅមូលដ្ឋាន បានរៀបចំជាកង ក្រុម ដើម្បីប្រមូលផ្តុំយកទៅបោះឆ្នោត ដោយយើងមិនអាចសន្និដ្ឋានថា សមាជិកទាំងអស់ដែលអញ្ជើញទៅបោះឆ្នោត បោះឱ្យគណបក្ស ក តែម្នាក់នោះទេ តែដោយខ្លាចគេមើលឃើញពេលគាត់ចូលទៅបោះឆ្នោត ហេតុនេះធ្វើឱ្យគាត់បង្វែរសតិអារម្មណ៍ ដោយគួសឱ្យគណបក្សផ្សេងខុសពីចិត្តគាត់ ដោយសារចេះតែមើលឃើញមានគេនៅពីក្រោយ ។ នេះជាការគាបសង្កត់ផ្នែកសតិអារម្មណ៍ ដូច្នេះសុំឱ្យ គជប ដូចលោកប្រធាន គជបខ ថា ធ្វើម៉េចកុំឱ្យអាជ្ញាធរមូលដ្ឋានគ្រប់គ្រងបញ្ហានេះបាន កុំឱ្យធ្វើបែបនេះទៀត ដោយសារប្រជាជនយើងសព្វថ្ងៃនៅមានការភ័យខ្លាចណាស់ មិនសូវហ៊ានពុះពារជាមួយនឹងរដ្ឋអំណាចនៅមូលដ្ឋានទេ ។ ទាក់ទិននឹងអំណោយ លោកមាន ប្រសាសន៍ថា សូមលោកពិនិត្យថាបើជាអំណោយរបស់រាជរដ្ឋាភិបាលឱ្យពិតជាអំណោយរបស់រាជរដ្ឋាភិបាល សំរាប់ចែកជូនពលរដ្ឋក្រីក្រ កុំឱ្យអំណោយនេះក្លាយជាអំណោយរបស់គណបក្សនយោបាយណាមួយ ។ រាល់បញ្ហាដែលបានលើកឡើង សូមអង្គប្រជុំជួលសំរួលឱ្យមានប្រសិទ្ធិភាពនៅពេលបោះឆ្នោត ។

លោក **ឱក សេរី សោភក្តិ៍** បានអរគុណដល់តំណាងគណបក្សហ៊្វុនស៊ិនប៉ិច ដែលមានប្រសាសន៍រួចមកនេះ ។ ដូចសព្វដងដែរ លោកបានជំរាប និងរំលឹកដល់អង្គប្រជុំថា យន្តការ ខប់សែល បានទទួលការគាំទ្រពីក្រសួងនានាច្រើនណាស់ ទាំងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គជប ក្នុងរូបមន្តនៃកិច្ចសហការថា បើសិន ខប់សែល បញ្ជូន សំណុំរឿងណាមួយ ក្រសួងទាំងនោះព្រមស៊ើបអង្កេតឱ្យ ។ ប៉ុន្តែនៅពេលប្រជុំ ខប់សែល កន្លងមកមានការលើកជាទូទៅ ដែលជាការពិបាកនឹងស៊ើបអង្កេតណាស់ បើមានករណីខុសឆ្គងនៅកន្លែងណា សុំឱ្យទីតាំងភូមិសាស្ត្រ អ្នកប្រព្រឹត្ត និងឈ្មោះករណីថាកើតឡើងយ៉ាងណានោះ ខប់សែល នឹងរៀបចំជូន ដោយសហការជាមួយ គជប និងក្រសួងមានសមត្ថកិច្ច ។ ដើម្បីឱ្យយន្តការមានប្រសិទ្ធិភាពក្នុងការបង្ការទំនាស់បាន លុះណាតែយើងដឹងថា តើមានបញ្ហាអ្វីកើតឡើងនៅកន្លែងណា បើយើងដឹងករណីច្បិចមួយ ហើយនិយាយជាទូទៅថា បើមេឃុំម្នាក់ធ្វើខុស ហើយយើងនិយាយថា មេឃុំទាំងអស់ផធ្វើខុស នេះមិនត្រឹមត្រូវទេ បើមេភូមិណាមួយធ្វើការសង្កត់សង្កិន ហើយចោទថា មេភូមិទាំងអស់ក្នុងឃុំធ្វើដូច គ្នាដែរ គឺមិនត្រឹមត្រូវទេ ។ សូមបង្ហាញ និងលើកករណីឱ្យច្បាស់ៗ នោះក្រសួងមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ នឹងធ្វើការស៊ើបអង្កេតជូន នៅខេត្ត នានា និងនៅថ្នាក់ជាតិ ក៏យើងធ្វើដូច្នោះដែរ ហើយដ៏មានប្រសិទ្ធិភាពទៀតផង ដរាបណាករណីមិនទាន់បិទ ខប់សែល តាមសួរជានិច្ចថា តើរឿងដែលគេលើកទៅដល់ណាហើយ មានដំណឹងទេ ដើម្បីជូនដំណឹងទៅសាមីខ្លួនវិញ ។

លោក **សម សៀន** លេខាធិកា គណបក្ស សមរង្ស៊ី ឃុំផ្ទះព្រៃ លោកសង្កេតឃើញថា ការបោះឆ្នោតកន្លងមក រៀបចំហាក់ដូចជារលូនគ្រាន់បើហើយ តាមមតិរបស់លោកផ្ទាល់ដែលជាគណបក្សមួយដែលលោក លោកស្រី តែងហៅថា គណបក្សប្រឆាំង ឃើញថានៅមិនទាន់បានប្រព្រឹត្តទៅបានរលូនមែនទែនទេ នៅមានកង្វល់ខ្លះពីពលរដ្ឋដែរ តែរៀបចំបានប្រសើច្រើនហើយ ។ យ៉ាងណាក៏នៅមានគុណវិបត្តិជាបន្តដែរ ដូចនេះដើម្បីឱ្យការបោះឆ្នោតក្រុម ប្រឹក្សាឃុំ-សង្កាត់ នៅឆ្នាំ២០០៧ និងបោះឆ្នោតជ្រើសរើសសភានៅឆ្នាំ២០០៨ នៅពេលខាងមុខ ត្រូវរៀបចំចុះបញ្ជីឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតបានល្អ ដោយលោកស្នើទៅ គជប ថា សុំឱ្យមាន គជប មួយដែលឯករាជ្យ អព្យាក្រឹត និងគ្មានលំអៀង ហើយពេលចុះឈ្មោះអ្នកបោះឆ្នោតសូម ពិនិត្យឱ្យបានច្បាស់លាស់ពីអត្តសញ្ញាណ ពិសេសថ្ងៃ ខែ ឆ្នាំកំណើត របស់ពលរដ្ឋ និងសុំកុំផ្លាស់ប្តូរបញ្ជីឈ្មោះអ្នកបោះឆ្នោត ឧទាហរណ៍ អ្នកចុះបោះ បោះឆ្នោត នៅការិយាល័យណា ពេលបោះឆ្នោត សូមឱ្យរក្សា ឈ្មោះអ្នកបោះឆ្នោត ឱ្យនៅការិយាល័យនោះដដែល កុំឱ្យពលរដ្ឋត្អូញត្អែរពីការផ្លាស់ប្តូរការិយាល័យ ដែលនាំឱ្យពិបាកដើរឆ្ងាយ និងមិនបានទៅបោះឆ្នោតជាង ១លាននាក់ ដោយសារតែការច្រឡំបញ្ជី ។ លោកក៏បានសំណូមពរដល់ស្នងការ ប៉ូលីសខេត្តក្នុងរៀបចំធ្វើអត្តសញ្ញាណប័ណ្ណ ឱ្យបានដល់ពលរដ្ឋគ្រប់រូប នៅពេលធ្វើបានហើយ សូមយកទៅចែកដល់ពលរដ្ឋផង ដោយសារអ្នកខ្លះបានធ្វើយូរហើយ តែមិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណ និងសុំកុំយកលុយច្រើនពេកពីពលរដ្ឋនៅមូលដ្ឋាន ដែលកន្លមកលោកមន្ត្រីប៉ូលីសយក ៣០០០៛ សំរាប់លិខិតនានា ហើយអ្នកសរសេរយក ៥០០-១០០០៛ ។ បើពលរដ្ឋគ្មានអ្វីសំអាង ត្រូវធ្វើទំរង់ ១០១៨ ដែលចាំបាច់មានរូបថតបិទ ២សន្លឹក ទើបអាចទៅបោះឆ្នោតបាន បើពលរដ្ឋគ្មានលុយ តើអ្នកណាអាចចេញជំនួសបាន? សូមជួយបំភ្លឺដល់ពលរដ្ឋផង ដោយហេតុថា ពលរដ្ឋគ្មានលុយថតរូបទេ ។ លោកបានសរសើរដល់ គជបខ ដែលធ្វើការបានល្អត្រឹមត្រូវតាមនីតិវិធី តែតាមការអនុវត្តន៍នៅថ្នាក់ក្រោមមិនទាន់បានល្អទេ សូមពង្រឹងបន្ថែមទៀត ហើយសំណូមពរដល់អង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដែលទៅពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងអ្នកសង្កេតការណ៍គណបក្ស ដែលបញ្ជូនសមាជិកមកពិនិត្យបញ្ជីនេះ សូមឱ្យយកចិត្តទុកដាក់មែនទែន ដោយសារលោកសង្កេតឃើញអ្នកទាំងនោះ គ្រាន់តែមកជជែកគ្នាលេងទេ មិនបានយកចិត្តទុកដាក់ទៅតាមការចាត់តាំង ដូច្នេះសូមឱ្យស្ថាប័ននានាជួយពិនិត្យទាំងអស់គ្នា ។

លោក **ជឹម ជរ** ជំទប់ទី ២ គណបក្ស សមរង្ស៊ី ឃុំបឹងបត់កណ្តាល លោកបានសួរយ៉ាងខ្លីទៅប្រធាន គជបខ ថា យុវជនគ្រប់អាយុ ១៨ឆ្នាំ និងអ្នកមិនទទួលបានប័ណ្ណពតិមាន តើពួកនេះមានសិទ្ធិទៅធ្វើប័ណ្ណបោះឆ្នោតឬទេ?

លោក **ជួង សំអាត** ជំទប់ទី ២ គណបក្ស សមរង្ស៊ី ឃុំផ្ទះរង លោកបានជំរាបទៅអង្គប្រជុំ និងអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ថា ថ្មីៗនេះយើងឃើញលោកមេភូមិជាប់ឆ្នោតតាមរយៈការបោះឆ្នោតពីសមាជិកក្រុមប្រឹក្សាឃុំ ដែលគាត់ជាមេភូមិរបស់គណបក្សប្រជាជន លោកមេភូមិហៅ លោកគ្រូម្នាក់សួរថា លោកចូលទៅគណបក្សនយោបាយណាជាច្រើនដង ។ ដូច្នេះលោកបានសួរ និងប្រាប់ទៅលោកអំ បិន សារឿន ថា លោកមេភូមិ ធ្វើបែបនេះ គឺជាការគំរាមកំហែង ហើយលោកគ្រូនោះមិនទាន់ចូលគណបក្សណាផង ហើយលោកមេភូមិ គំរាមទៀតថា គេឃើញឈ្មោះលោកគ្រូនោះ នៅក្នុងគណបក្ស សម រង្ស៊ី សុំលោកពិនិត្យមែនទែន ហើយប្រពន្ធលោកគ្រូនោះ បានទៅជួបតំណាងគណបក្ស សម រង្ស៊ី ឃុំតេរុង ឱ្យលុបចេញ លោកមេភូមិថា មិនបាច់លុបទេ គេឃើញពីរដងហើយ ចាំមើលលើកទី ៣ គេនឹងប្ដឹង ។ លោកឆ្ងល់នឹងហេតុការណ៍នេះ និងសូមសំណូមពរដល់ ឯកឧត្តមថ្នាក់ខេត្ត ស្រុកថា មេត្តាទៅបង្រៀនលោកមេភូមិនោះឱ្យចេះធ្វើការដោយបើកទូលាយឱ្យពលរដ្ឋមានសិទ្ធិជាពលរដ្ឋ និងនយោបាយ កុំបំភិតបំភ័យ ។ សុំកុំអនុវត្តតាមសម័យ ៣ឆ្នាំ ដោយសារអាជ្ញាធរភូមិនៅមូលដ្ឋាន (ភូមិក្រញ៉ាំ) ដាក់កំលាំងតាមដាន នរណាចូលគណបក្សណា នេះមានតែរបបផ្ដាច់ការទេ ទើបធ្វើបែបនេះ ។

លោក **អ៊ឹម សាមិន** មេឃុំត្រពាំងជង ស្រុកបាកាន គណបក្ស ប្រជាជន បន្ទាប់ពីបានស្ដាប់ប្រសាសន៍របស់តំណាងស្ថាប័ននានារួចមកបានយល់ពីខ្លឹមសារ និងគោលបំណងនៃការពិភាក្សាព្រឹកនេះ ដែលបង្កឱ្យមានវប្បធម៌ ជជែកទល់មុខ យកបញ្ហានានា មកដោះស្រាយរួមគ្នា ។ កន្លងមកការបោះឆ្នោតនៅតាមមូលដ្ឋានមិនសូវមានបញ្ហាអ្វីធ្ងន់ធ្ងរទេ ទោះយ៉ាងណានៅបន្តិចបន្តួច ដូចជាការវាយប្រហារពាក្យសំដីពីក្រោយខ្នង ពាក្យវាយប្រហារតចំពោះមុខ មិនទាន់មានអ្វីធំដុំទេ ។ តាំងពីបោះឆ្នោតឆ្នាំ២០០២ មក មាន ៣ គណបក្សធ្វើការរួមគ្នាតាំងពីពេលនោះដោយរលូន មិនមានបញ្ហាគួរកត់សំគាល់ទេ រវាងគណបក្សដៃគូក្នុងរាជរដ្ឋាភិបាល ។ នៅមានបញ្ហាមួយចំនួនទាក់ទងជាមួយប្រជាពលរដ្ឋ មិនទាក់ទិនដល់គណបក្សនយោបាយទេ តែវាជារឿងដែលស្មុគស្មាញ ។ លោកពិនិត្យឃើញថា កាលពីឆ្នាំ១៩៩៣ បោះឆ្នោតរៀបចំដោយអ៊ុនតាក់ ពលរដ្ឋខ្មែរដែលទើបងើបពីរបបខ្មែរក្រហម និងរដ្ឋកម្ពុជា មិនដែលបានបោះឆ្នោតម្តងណាទេ ដូច្នេះម្នាក់ៗសស្រាក់ សស្រាំ ទៅចុះឈ្មោះបោះឆ្នោត ដែលការចុះនេះ មិនបានប្រាកដទេ ។ លោកជំរាបដោយត្រង់ថាជួនកាលពលរដ្ឋចុះបញ្ជីបីដង សឹងខុសទាំងបីដងដែរ ។ ចុះឈ្មោះខុស ធ្វើម៉េចអាចបោះឆ្នោតបាន ដោយសារលោកពិនិត្យឃើញថា ប័ណ្ណឆ្នាំ១៩៩៣ នៅពេលចុះឈ្មោះដដែល ដល់មក ១៩៩៨ ២០០២ ២០០៣ ចេះតែបោះបាន តែនេះជាពេលវេលាមួយដែលកម្ពុជា មានការវិវត្តចំរើន កម្ពុជាម្ចាស់ការដោយខ្លួនឯងបាន ដែលទាមទារឱ្យម្នាក់ៗមានអត្តសញ្ញាណប័ណ្ណពលរដ្ឋខ្មែរ ។ ការបោះឆ្នោតលើកក្រោយនេះ គឺ យកតែប័ណ្ណដែលចេញដោយរាជរដ្ឋាភិបាល មានទាំងពីនគរបាលជាតិ កងរាជអាវុធហត្ថ ឬធាយារបស់ព្រះសង្ឃ នោះទើបអាចប្រើការបាន ។ លោកបានធ្វើការពិនិត្យនៅក្នុងឃុំត្រួសៗ ដោយផ្ទៀងជាមួយប័ណ្ណព័តិមាន ១៨១នាក់ ត្រូវបានតែ ៨៦នាក់ទេ ។ នេះជាបញ្ហាពិបាកក្នុងការកែតំរូវ ដោយសារ គជប បានទុកពេលត្រួតពិនិត្យដែរ ឈប់ចែកប័ណ្ណពតិមាននៅខែសីហា ពិចារណាកែតំរូវឈ្មោះនៅខែកញ្ញា និង ចាប់ពីថ្ងៃ ០១-២០ ខែតុលា ចុះឈ្មោះស្រេចបាច់ ។ ស្មៀន នឹងមានការមមាញឹកខ្លាំងនៅពេលនោះ តែមានការឯកភាពនៅថ្នាក់ជាតិ មិនអនុញ្ញាតឱ្យមានសិក្ខាសាលា ចំអំឡុងពេលនេះទេ ដើម្បីឱ្យការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតបានចប់សព្វគ្រប់ និងត្រឹមត្រូវ ដែលកាលពីពេលកន្លងទៅ ស្មៀនតែងរវល់ទៅប្រជុំ ។ តាំងពេលនោះ ដល់ពេលនេះ ពលរដ្ឋបានយល់ច្បាស់ពីតួនាទីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបំរើជាតិ ដោយបានបង្ហាញតាមរយៈការទៅចូលរួមបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត

ពិសេសនៅពេលចែកប័ណ្ណពតិមាន ទោះជាប់ដកស្ទូងយ៉ាងណា ក៏ផ្លាស់វេនគ្នាមកទទួលប័ណ្ណ កន្លែងណាធ្វើមិនទាន់ ហើយ ទុកឱ្យភូមិធ្វើបន្ត ។ នេះជាវិធីសាស្ត្រឃុំ ធ្វើទៅតាមការណែនាំរបស់ គជបខ ។ ការពិបាកដែលជួបប្រទះ គឺអ្នកទៅរកស៊ី នៅក្រៅមូលដ្ឋាន តាមព្រំដែនថៃ និងអ្នកធ្វើការនៅតាមរោងចក្រ ដែលមិនជាពិបាកណាស់ទេ តែផ្លាស់មកច្រើនពេក ធ្វើមិនទាន់ ។

លោក **ឱក សេរី សោភក្តិ** បានជំរាបជូនអង្គប្រជុំបន្ថែមទៀតថា យន្តការខប់សែល ឱ្យតំលៃទៅលើតួនាទីស្ត្រីខ្លាំងណាស់ ក្នុងការចូលរួម ពិសេសក្នុងជីវិតនយោបាយ នៅថ្នាក់មូលដ្ឋាន ព្រោះយើងគិតថា ប្រទេសមួយដែលមានពលរដ្ឋស្ត្រី ៥២% មិនអាចគ្មានការចូលរួមពីស្ត្រីបានទេ ។ ដរាបណាមាន ការចូលរួមពីស្ត្រីខ្លាំង នោះឆ្លុះបញ្ចាំងឱ្យឃើញនូវភាពស្វាហាប់ ម៉ត់ចត់ លើការចែករំលែកក្នុងសង្គម និងប្រទេសជាតិនោះបានរីកចំរើន ។ លោកបានអញ្ជើញអ្នកចូលរួម ដែលជាស្ត្រីទាំងអស់ មានប្រសាសន៍ថាតើបញ្ហាដែលស្ត្រីជួបប្រទះនៅខេត្តពោធិសាត់យ៉ាងណាខ្លះក្នុងយន្តការនៃការបោះឆ្នោត ។

លោកវីរៈសេនីឯក **ហែន វុទ្ធា** ស្នងការនគរបាលខេត្ត លោកបានបង្ហាញជូនអង្គប្រជុំអំពីការងារធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់ពលរដ្ឋ ។ មុននឹង ជំរាបជូនបញ្ហានានាដែលវាគ្មិនបានលើកឡើង លោក បានរាយការណ៍ពីទិន្នន័យនៃការងារអត្តសញ្ញាណប័ណ្ណថា ខេត្តពោធិ៍សាត់ដែលមាន ៦ស្រុក ចំនួនពលរដ្ឋគ្រប់អាយុ ១៨ឆ្នាំឡើង ហើយដែលបានចុះក្នុងបញ្ជីដើម្បីធ្វើអត្តសញ្ញាណប័ណ្ណ ព្រោះថា មុននឹងការបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណ ចាំបាច់ត្រូវមានឈ្មោះចុះក្នុងបញ្ជីពលរដ្ឋអាយុ ១៨ឆ្នាំ មានសញ្ជាតិខ្មែរ ហើយបានសុំចុះឈ្មោះបំពេញបែបបទ ចំនួន ២០៥.៩៩៧នាក់ ។ យើងបានចុះ ធ្វើនៅតាមស្រុក និងឃុំនីមួយៗបាន ៥ដងហើយ ហើយបានសំរេចផ្តល់ជូនពលរដ្ឋបាន ១៧៧.៧៥៩នាក់ ឃើញថា នៅមានចំនួននៅសល់ក្នុងបញ្ជី និងអ្នកដែលមិនទាន់បានបំពេញបែបបទ កំពុងបន្តធ្វើ ចំនួន ២៨.២៣៨នាក់ ដោយសារពួកគេទៅរកស៊ីឆ្ងាយ (៨.៦៩៥នាក់) បាត់មុខ ដែលបានស្រង់ នៅតាមមូលដ្ឋានភូមិឃុំ ក្រោយពីបានចុះឈ្មោះហើយ គាត់មានភារកិច្ចទៅបួសចំនួន ៦១៥នាក់ ខ្លះដោយសារមានជម្ងឺ ១៤០នាក់ ចំពោះអ្នកដែល គ្រប់អាយុ ១៨ឆ្នាំ ចាស់ជរាមាន ២.៤០៨នាក់ អ្នក ជាប់ពន្ធនាគារ ១៥នាក់ ឆ្កួតចំនួន ១០៩នាក់ ស្លាប់ ៣០នាក់ សរុប ១៥.២១៤នាក់ អ្នកដែលមានមូលហេតុហើយមិនបានផ្តល់អត្តសញ្ញាណប័ណ្ណ ។ ដូច្នេះនៅសល់ ១៣.០២៤នាក់ ដែលសង្ឃឹមថា នឹងអាចធ្វើបាន ។ នេះជាតួលេខលំអិត ទទួលបានពីមូលដ្ឋាននៃស្រុកទាំង ៦ របស់ខេត្ត ។ ស្របតាមការណែនាំពីការផ្តល់អត្តសញ្ញាណប័ណ្ណជាតិនៃក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ស្នងការខេត្តបានជំរុញការងារនេះខ្លាំងណាស់ ដោយនឹងបញ្ចប់ការចុះធ្វើ និងផ្តល់អ្នកដែលមានឈ្មោះក្នុងបញ្ជីនៅខែធ្នូ ២០០៦ ។ នៅខេត្តពោធិ៍សាត់ កន្លងមកមានម៉ាស៊ីន ឬក្រុមផ្តល់អត្តសញ្ញាណប័ណ្ណតែមួយគ្រឿងទេ ក្រោយមកថ្មីនេះ ទើបទទួលបានមួយគ្រឿងទៀត ធ្វើឱ្យការងារផ្តល់អត្តសញ្ញាណប័ណ្ណ មានពីរក្រុម ក្នុងរយៈកាល ១៥ថ្ងៃមុននេះ យើងបានសំរុកធ្វើនៅស្រុកសំពៅមាស លើកទី ៥ ។ ចាប់ពីថ្ងៃទី ១៤-១៦ សីហា បានទៅធ្វើនៅស្រុកវាលវែងចំនួនជាង ៨០០នាក់ ដែលបានមកធ្វើអត្តសញ្ញាណប័ណ្ណ ។ នៅពេលធ្វើ ម្ចាស់អត្តសញ្ញាណប័ណ្ណ ត្រូវបំពេញបែបបទដោយខ្លួនឯង និងបានចុះហត្ថលេខា ផ្តិតមេដៃ ទាំង ១០ម្រាម ព្រោះវាជាប័ណ្ណដែលមានសារៈសំខាន់ជាងគេបំផុត ។ ឈ្មោះនៅក្នុងប័ណ្ណនោះ សាមីខ្លួនសន្មតថា មិនមានការប្រែប្រួលទេ ព្រោះបានចុះហត្ថលេខាទាំង ១០ម្រាមហើយ ។ ជួនកាលយើងធ្វើហើយ តែមិនបានចែកភ្លាមៗ ធ្វើឱ្យយឺតយ៉ាវ ជួនកាលដោយសារថតភ្លាម មិនបានទេ ព្រោះត្រូវបញ្ជូនមកភ្នំពេញ និងបញ្ចូលឈ្មោះ ដែលអាចមានខុសខ្លះដែរ ក្រោយមកបញ្ជូនឱ្យអភិបាលខេត្តចុះហត្ថលេខា ។

លោកមិនបដិសេធ ចំពោះរឿងមន្ត្រីនគរបាលយកលុយពីពលរដ្ឋនៅក្នុងរឿងធ្វើអត្តសញ្ញាណប័ណ្ណនេះទេ ។ ជាក់ស្តែងការបញ្ចូលទិន្នន័យផ្សេងៗដោយក្រសួងមហាផ្ទៃ មិនបានយកលុយមែន តែការដឹកជញ្ជូនម៉ាស៊ីន ប្រេងសាំង ដែលយើងបានប្រជុំជាមួយ

អភិបាលស្រុក ឬតំណាងអភិបាលស្រុក ឃុំ មុននឹងចុះទៅស្រុកណាមួយ អំពីចំណាយផ្សេងៗ ដោយមានការឧបត្ថម្ភខ្លះដែរ ។ នៅពេលប្រជុំថ្នាក់ស្រុក យើងបានប្រជុំច្បាស់ថា ចំពោះពលរដ្ឋដែលគ្មានលទ្ធភាព មិនបាច់បង់លុយទេ បើបងប្អូនមានលទ្ធភាព សូមជួយឧបត្ថម្ភក្រុមការងារនេះផង ។ ជាក់ស្តែងក្នុងឃុំចំរើនផល ស្រុកសំពៅមាស ដែលទើបបានបញ្ចប់ម្សិលមិញនេះ មិនបានប៉ះពាល់រឿងយកលុយទេ ដូច្នេះបើគ្មានលុយក៏ធ្វើអត្តសញ្ញាណប័ណ្ណបានដែរ ឱ្យតែទៅដល់កន្លែងធ្វើ ។ បើមានបញ្ហាថា ពលរដ្ឋបានទៅដល់កន្លែងហើយ មិនបានធ្វើអត្តសញ្ញាណប័ណ្ណ សូមលើកឱ្យចំឈ្មោះ នៅភូមិ ឃុំណា ព្រោះពេលធ្វើ មានវត្តមានឃុំ ភូមិ ស្រុកនៅទីនោះ លើកលែងតែពលរដ្ឋនោះនៅក្រៅមូលដ្ឋាននោះ ទើបធ្វើមិនបាន ។ អ្នកនៅក្នុងអង្គហេតុ គឺមានលោកអភិបាល ស្រុកជាប្រធានគណៈកម្មការផ្តល់អត្តសញ្ញាណប័ណ្ណថ្នាក់ស្រុក ជាមួយអង្គហេតុឯទៀតៗមានភូមិ ឃុំ ចូលរួមទាំងអស់គ្នា កុំនៅក្រៅបញ្ហា ។ ការផ្តល់ នេះ ក៏ធ្វើទៅតាមច្បាប់ដែរ បើអ្នកស្នាក់នៅបណ្តោះអាសន្ន មិនអាចធ្វើជូនបានទេ លុះត្រាតែអ្នកមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងភូមិ ឃុំនោះ បើមាន ការខ្វះខាតយ៉ាងណា ស្នងការខេត្តនឹងខិតខំសំរបសំរួលជូនតាមរយៈអភិបាលស្រុក ឃុំ ផ្តល់ជូនឱ្យអស់ តាមការណែនាំពីក្រសួងមហាផ្ទៃ ។

លោក **ឱក សេរី សោភក្តិ** បានជំរាបអង្គប្រជុំថា បានដើរតាមខេត្តច្រើនណាស់ និងបានជជែករឿងផ្តល់អត្តសញ្ញាណប័ណ្ណនេះទាំងនៅថ្នាក់ជាតិដែរ ហើយនៅពេលបានចម្លើយណាមួយ ដែលមានភាពស្មោះត្រង់ យើងអាចដឹងបាន ។ ចម្លើយដែលលោកស្នងការបានឆ្លើយ មានភាពស្មោះត្រង់ណាស់ ។ ចំណុចដែលនៅមិនទាន់ឯកភាព មិនថាតែរឿងអត្តសញ្ញាណប័ណ្ណទេ ចំណែកការផ្តល់សេវាដល់ពលរដ្ឋ គឺរាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យយកលុយកាក់ទេ តែសភាពការណ៍ជាក់ស្តែង នៅពេលអនុវត្តសេវាត្រូវតែយក ដើម្បីបំពេញកង្វះខាតនានា ។ ពលរដ្ឋតាមមូលដ្ឋាន មិនមែនថាមិនជូនទេ ឱ្យតែផ្តល់សេវាដល់ដៃ នឹងជូនបានតែត្រូវកំណត់ថា ប៉ុន្មានឱ្យត្រូវគ្នា? បើមិនឯកភាពគ្នាទេ ហាក់ដូចជាបានបើកឱកាសដល់មន្ត្រីមួយចំនួនតូច ឆ្លៀតយកចំណេញច្រើន ។ បើសំរេចថាប៉ុន្មាន សំរាប់ចំណាយលើអាហារ និងការធ្វើដំណើរ ពលរដ្ឋមិនចិត្តអាក្រក់ មិនចង្អៀតចង្អល់ទេ តែសុំឱ្យដឹងច្បាស់ប៉ុន្មានសមស្រប នឹងជីវភាព របស់ពលរដ្ឋ ។ បើឃើញថាពលរដ្ឋពិតជាក្រមែន សុំកុំយកលុយពីពលរដ្ឋនោះ ដែលយើងនឹងរាយការណ៍បញ្ហានេះទៅក្នុងកិច្ចប្រជុំថ្នាក់ជាតិ ។ ឯកឧត្តម ឧប នាយករដ្ឋមន្ត្រីបានយកចិត្តទុកដាក់ណាស់ក្នុងរឿងផ្តល់អត្តសញ្ញាណប័ណ្ណនេះ យើងរកដំណោះស្រាយជាមួយគ្នាក្នុងយន្តការ ខប់សែល នោះយើង នឹងសំរេចដល់គោលដៅ ។

លោក **សម សៀន** បានយល់ស្របនឹងយោបល់លោកស្នងការតែសូមសំណូមពរថា ពលរដ្ឋតែងត្អូញអត់មានលុយ តែមន្ត្រីដែលធ្វើអត្តសញ្ញាណប័ណ្ណ មិនដែលសួរនាំពលរដ្ឋក្រីក្រនោះទេ ។ បើបានធ្វើអត្តសញ្ញាណប័ណ្ណហើយ សុំបញ្ជូនមកមូលដ្ឋានកុំឱ្យគេចោទថាលោកចេះតែលាក់ផ្ទឹមអត្តសញ្ញាណប័ណ្ណណាដែលជាសមាជិកគណបក្ស សម រង្ស៊ី តែចំពោះអ្នកដទៃ តែងទទួលបានជាបន្តបន្ទាប់ នេះជាចំណុចដែលលោកចង់លើកបង្ហាញ និងសុំឱ្យលោកស្នងការមានវិធានការសំរួលការងារនេះ សុំឱ្យអព្យាក្រឹតមិនប្រកាន់បក្សពួក និងដោយស្មោះត្រង់ទាំងអស់គ្នា ។

លោកស្រី **ព្រុំ បូណា** ប្រជាពលរដ្ឋ ភូមិព្រៃកស្តី សង្កាត់លលកស ស្រុកសំពៅមាស ខេត្តពោធិសាត់ លោកស្រីជាពលរដ្ឋម្នាក់ដែលរងគ្រោះ ពីគណបក្សធំទាំងពីរ ។ លោកស្រីមានប្រសាសន៍ទាំងទឹកភ្នែកថា ពេលលោកស្រីទៅបោះឆ្នោត គណបក្ស ប្រជាជនចោទថា លោកស្រីជាសមាជិក គណបក្សហ៊្វុនស៊ិនប៉ិច ហើយហ៊្វុនស៊ិនប៉ិចថា លោកស្រីជាសមាជិកគណបក្សប្រជាជន ត្រង់នេះហើយដែលលោកស្រីរងនូវការគាបសង្កត់ពីគណបក្សធំៗទាំងពីរ រហូតដល់មិនអាចប្រកបរបររកស៊ី និងយកសមត្ថភាពដែលមានទៅស្វែងរកការងារ

ធ្វើបន្តិចបន្តួច ក៏មិនបានដែរ ដោយសារលោកស្រីគ្មាន ដីស្រែចំការសំរាប់ប្រកបរបរទេ រស់នៅលើដីតូចមួយដុំ ហើយរងគ្រោះធម្មជាតិ ទឹកជំនន់រាល់ឆ្នាំ ។ គេតែងបង្ខិលឱ្យទៅសុំគណបក្សផ្សេង នៅពេលលោកស្រីទៅសុំអំណោយ ។ នេះជាការរងគ្រោះរបស់លោកស្រី និង កូនតូចៗ ។ ថ្ងៃនេះសុំឱ្យ ខប់សែល ជួយផ្តល់ដំណឹងនេះទៅដល់ថ្នាក់លើផង ។

លោក **ពៅ ឃឹម** ជំទប់ទី ២ ឃុំបឹងភ្ន គណបក្ស សមរង្ស៊ី តាមប្រសាសន៍របស់លោកប្រធានលេខាធិការដ្ឋានថា មុននឹងធ្វើការចែកប័ណ្ណព័ត៌មានបោះឆ្នោត លោកបានអញ្ជើញគ្រប់ភាគីពាក់ព័ន្ធក្នុងការងារនេះ មកចូលរួមស្តាប់ការណែនាំ និងបទបញ្ជានានាទាំងអស់គ្នា តែសំរាប់សមាជិកគណបក្ស សម រង្ស៊ី នៅតាមឃុំនានា ក្នុងស្រុកបាកានថា មិនមានដំណឹងអ្វីទាំងអស់ពីរឿងនេះ ។ ឯនៅឃុំបឹងខ្នាវិញ តាមការប្រជុំជាមួយលោកប្រធានក្រុមប្រឹក្សាឃុំបានណែនាំថា សុំឱ្យអ្នកដែលចែកប័ណ្ណព័ត៌មានចុះតាមផ្ទះ ដើម្បីឱ្យពលរដ្ឋទទួលបាន តែអ្នកនោះមិនបានអនុវត្តតាមការណែនាំទេ បែរជាប្រកាសមីក្រូចែកទៅវិញ ដូច្នេះដំណើរការនេះ មានការយឺតយ៉ាវបំផុត ។ លោកសំណូមទៅ គជបខ ថា សូមណែនាំទៅភ្នាក់ងារចែកនោះថែមទៀត ដើម្បីថ្នាក់ក្រោមឱ្យអនុវត្តការងារតាមការណែនាំ ដោយចុះចែកដល់ផ្ទះឱ្យបាន ១០០% ព្រោះខែនេះពលរដ្ឋរវល់ធ្វើស្រែ ហើយពុំសូវយល់ពីសារៈសំខាន់នៃប័ណ្ណព័ត៌មានអ្នកបោះឆ្នោតទេ ដូច្នេះមិនយកចិត្តទុកដាក់លើវាទេ សូម្បីតែអត្តសញ្ញាណប័ណ្ណដែលសំខាន់បំផុតនោះ ក៏មិនសូវយកចិត្តទុកដាក់ដូចគ្នាដែរ ដូចជាអ្នកខ្លះថាមិនដឹងយកវាធ្វើអីផង ។

លោកស្រី **វឹន សុខុម** មេឃុំស្រែ្ត ស្រុកភ្នំក្រវ៉ាញ មានប្រសាសន៍ទាក់ទិននឹងការចុះឈ្មោះអ្នកបោះឆ្នោតដែលពីរសប្តាហ៍មុន លោកស្រីបានចុះចែកប័ណ្ណពត៌មានអ្នកបោះឆ្នោតនៅតាមភូមិដាច់ស្រយាលនានា ដូចជាភូមិនាងខ្វាវ ភូមិមុល ភូមិជើ ដោយបានជួបប្រជាពលរដ្ឋមួយចំនួនថា គាត់បានចុះឈ្មោះបោះឆ្នោតដែរតែមិនបានទទួលប័ណ្ណពត៌មាន លោកស្រីបានជំរាបទៅវិញថា បងប្អូនបានចុះឈ្មោះច្រើនមែន តែមិនបានទៅបោះឆ្នោតទេកាលនោះដោយសារបងប្អូនជាប់ទឹកជំនន់ ហើយអ្នកដែលមកបោះឆ្នោតបានតែ ២០-៣០នាក់ទេកាលនោះ ។ ដូចនេះប្រជាពលរដ្ឋក៏សួរថា តើនៅពេលបោះឆ្នោតលើកក្រោយឱ្យគាត់ទៅបោះនៅទីណា ? ហើយពួកគាត់សុំឱ្យដាក់ការិយាល័យនៅវត្តស្រែ្តចាស់ដដែល ។ មួយវិញទៀតឈ្មោះដែលមានប័ណ្ណបោះឆ្នោតហើយ ឥឡូវផ្សព្វផ្សាយឱ្យមកថតរូបធ្វើអត្តសញ្ញាណប័ណ្ណ ដល់ពេលមកធ្វើច្រើនតែអ្នកគ្រប់អាយុ ១៨ឆ្នាំឡើង ឯអ្នកផ្សេងទៀតមិនបានមកធ្វើ ដោយស្មានតែធ្វើអ្នកដែលមានអាយុ ១៨ឆ្នាំ ជាពិសេសប្រជាពលរដ្ឋមួយចំនួនដែលនៅជនបទដាច់ស្រយាលគាត់អត់បានដឹងទេថា ខ្លួនគាត់ដែលអត់មានអត្តសញ្ញាណប័ណ្ណត្រូវមកធ្វើដែរ ។ ដូច្នេះពិនិត្យដោយត្រួសៗទៅឃុំលោកស្រីមានពលរដ្ឋខ្វះអត្តសញ្ញាណប័ណ្ណប្រហែលជាង ៣០០នាក់ ។ ដូច្នេះលោកស្រីបានសន្ទូមពរដល់ក្រុមចុះធ្វើអត្តសញ្ញាណប័ណ្ណមេត្តាចុះដល់ឃុំលោកស្រីម្តងទៀតផង ហើយលោកស្រីបានប្រកាសប្រាប់ពលរដ្ឋថា បើក្រុមចុះធ្វើអត្តសញ្ញាណប័ណ្ណមកម្តងទៀតសុំអញ្ជើញមកធ្វើអត្តសញ្ញាណប័ណ្ណឱ្យបានទាំងអស់គ្នាទោះរវល់ទៅណាក៏ដោយត្រូវមកធ្វើប័ណ្ណនេះសិន ។

លោក**អ៊ុម ប៊ុនសឿន** មេឃុំអូតាប៉ោង គណបក្ស ប្រជាជន លោកបានតាមដានការចែកប័ណ្ណព័ត៌មានបោះឆ្នោតបានជិតដល់ដែរ ព្រោះ គជបខ បានអញ្ជើញមេភូមិ និងក្រុមប្រឹក្សាឃុំ មកចូលរួមស្តាប់ការណែនាំ ពីការចែកចាយប័ណ្ណនេះ ។ តាំងពីទទួលបានការណែនាំ ឃុំលោកបានចាប់ផ្តើមធ្វើ ការតាំងពីពេលនោះរហូតមកដល់ពេលនេះ មានអ្នកចុះឈ្មោះបោះឆ្នោត ៧.៩៩៥នាក់ ហើយទើបតែចែកបានជាង ៣.៥០០នាក់ប៉ុណ្ណោះ លោកបារម្ភនឹងប្រតិទិនការងារ និងបានតាមដាន (ទោះជាមានគេថាលោក លំអៀងក៏ដោយ) អ្នកណាខ្លះ

រស់ទៅស្រុងដែរទេ បើមិនទៅទេ នឹងណាត់ជាមួយដើម្បីផ្តល់ប័ណ្ណជូនគាត់ ស្រាប់តែដល់ពេលណាត់ទៅស្រុងបាត់ ដូចជា នៅភូមិអូតាប៉ោង លោកផ្តល់ជូនបានតែ ៣០នាក់ទេក្នុងមួយថ្ងៃ ។ ដោយសារ បានកំរៃពីការងារនេះខ្លះដែរ ដូច្នេះមេភូមិដែលទទួលបាន ៣ដុល្លារក្នុងមួយខែ ចែកគ្នាធ្វើការជាមួយជំនួយការពីរនាក់ទៀត គាត់រវល់តាមរកឈ្មោះពលរដ្ឋក្នុងភូមិ គ្មានថ្ងៃទំនេរសោះ ។ ភាគច្រើនពលរដ្ឋរវល់ទៅស្រុង ទើបធ្វើឱ្យការចែកនោះយឺត ដូច្នេះបើមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ នោះនឹងជំរុញការងារនេះ បានលឿនទៅមុខជាមិនខាន ។

លោក **អ៊ុង សាវ៉ាត** ជំទប់ទី ២ ឃុំមេទឹក គណបក្ស សមរង្ស៊ី តាមការសង្កេតឃើញថាមានភាពសាំញ៉ាំរវាងមន្ត្រីចុះឈ្មោះបោះឆ្នោត និងអ្នកចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត ផ្ទៀងផ្ទាត់ជូនពលរដ្ឋ ។ តែជំលោះនេះ ជារឿងតូចតាច ដោយសារយើងបានយោគយល់គ្នា ។ លោកក៏សង្កេតឃើញដែរថា ទិន្នន័យនៅក្នុងប័ណ្ណព័តិមានអ្នកបោះឆ្នោតមានខ្វះចន្លោះច្រើន ជួនកាលការិយាល័យមានបាត់ឈ្មោះពីក្នុងបញ្ជីផ្ទៀងផ្ទាត់ក្នុងទិន្នន័យឆ្នាំ២០០៥ ។ នេះជាបញ្ហាចោទដែលលោកចង់លើកឡើង ក្រៅពីនោះមានបញ្ហានានាដែរ តែអាចនិយាយគ្នាបាន តែលោកបានស្នើទៅ គជបខ ថា សូមកុំតំរូវឱ្យមានរូបថតទំរង់ ១០១៨ ដោយសារពលរដ្ឋមិនខ្វល់ពីការថតរូប បំពេញបែបបទអ្វីទេ ដោយហេតុថា យើងមានអ្នកចេះដឹងតែ ២០% នៃពលរដ្ឋទេដែលយល់ដឹងពីការងារនេះ ដែលមានស្ថាប័ននានាខំប្រឹងប្រែងនិងជំរុញការងារនេះ ដើម្បីឱ្យពលរដ្ឋបានជ្រាបអំពីដំណើរការនេះ ។

លោក **ផាន់ វណ្ណសិទ្ធិ** សូមឆ្លើយសំណួរវាគ្មិនខាងដើមដោយដុំៗ និងទៅតាមផ្នែក ។ បញ្ហាប័ណ្ណព័តិមានអ្នកបោះឆ្នោត គឺជាចំណុចរសើប និងគួរឱ្យចាប់អារម្មណ៍ខ្លាំងជាងគេ ដែលយោងស្មារតីអង្គប្រជុំណែនាំរបស់ គជបខ កន្លងមក យើងបានជំរាបជូនរួចរាល់អស់ហើយ ដោយសុំគោលការណ៍ពីអាជ្ញាធរខេត្ត បានអញ្ជើញឯកឧត្តមអភិបាលខេត្ត និងតំណាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល ឆ្លៀតពេលនោះក៏បានអញ្ជើញអាជ្ញាធរស្រុកឱ្យមកចូលរួមស្តាប់ដែរ ដើម្បីឱ្យដឹងពីគោលបំណងនៃផែនការចែកប័ណ្ណនេះ ។ បន្ទាប់មកបានកំណត់ផែនការទៅតាមមណ្ឌល ប្រមូលផ្តុំទៅតាមស្រុក ដោយបានអញ្ជើញក្រុមប្រឹក្សាឃុំ និងមេភូមិដែលជាអ្នករួមសហការមកធ្វើជាមួយគ្នា ដោយចាប់ធ្វើពីថ្ងៃទី ០១ សីហា ហើយការប្រជុំណែនាំបានធ្វើនៅថ្ងៃ ២៦-២៩ កក្កដា បានធ្វើចប់គ្រប់ស្រុកទាំងអស់ហើយថ្ងៃ ៣១ កក្កដា បានបញ្ជូនសំភារៈទៅដល់ឃុំ ។ ការប្រតិភូកម្មអំណាចទៅក្រុមប្រឹក្សាឃុំ ដែលមានទាំងជំទប់ និងមេឃុំ ត្រូវចាត់អ្នកទទួលខុសត្រូវការងារ ជាមួយភូមិដែលមានជំនួយការពីរនាក់ទៀត ហើយ គជបខ ផ្តល់សាហ៊ុយ ៤០ដុល្លារ ។ លោកបានជំរាបច្បាស់ណាស់នៅតាមក្រុមប្រឹក្សាឃុំនីមួយៗ នៅមូលដ្ឋានលោកមាន ១០ភូមិ ចែកជាភូមិលើទឹក ភូមិក្នុងព្រៃ និងភូមិកណ្តាលទីប្រជុំជន ដែលឃុំកំណត់តាមកាលវិភាគ ដែលជួនកាលក៏ពឹងមេក្រុមជួយដែរ និងណាត់ពលរដ្ឋឱ្យចាំទទួល ។ ដោយអ្នកខ្លះថា ពិបាកយល់ប្រតិទិន ទើបលោកមានចេញសេចក្តីណែនាំមួយផ្សេងទៀតដោយបញ្ជាក់ថា ក្នុងមួយខែនេះត្រូវចែកប័ណ្ណព័តិមានឱ្យចប់ ។ ពលរដ្ឋសរុបក្នុង ខេត្តមានជាង ១៩០.០០០នាក់ ហើយមានអ្នកទទួលខុសត្រូវ ៤៩នាក់ ដែលការចែកនោះមានពីរប្រភេទគឺ តាមសាមីខ្លួន និងតាមរយៈតំណាងក្នុងគ្រួសារ ភូមិធ្វើការណាត់ជាមួយពលរដ្ឋ បើគ្រួសារណារវល់ទៅស្រុងសូមទុកម្នាក់ដែលពេញវ័យចាំទទួលប័ណ្ណពតិមាន ។

នៅពេលផ្ទៀងផ្ទាត់ដែលមានរយៈពេលមួយខែ ដើម្បីរកឯកសារផ្លូវការណាមួយជាគោល បើឃើញខុសសូមទៅប្រាប់ស្មៀនឱ្យធ្វើការកែ តំរូវ ដែលសំខាន់ចាប់ពីថ្ងៃទី០១-២០ តុលា និងចុះឈ្មោះថ្មី ។ លោកបានយកសេចក្តីណែនាំទៅចាក់ផ្សាយតាមវិទ្យុធំៗ ពីរនិងទូរទស្សន៍មួយ ហើយសារពតិមានផ្សេងៗក៏មានផ្សព្វផ្សាយអំពីប័ណ្ណព័តិមាននោះដែរ បើមានការខ្វះចន្លោះ ប្រហែលជាមកពីមិនបានចាប់អារម្មណ៍ និងមិនបានប្រាស្រ័យទាក់ទងជាមួយខ្សែបណ្តាញគាត់ វាមិនមែនជាប័ណ្ណសំរាប់យកទៅបោះឆ្នោតទេ តែជាប័ណ្ណផែនទី

បង្ហាញផ្លូវសំរាប់គាត់ដើរទៅការិយាល័យបោះឆ្នោត ដោយមិនចាំបាច់ពឹងអ្នកណាទេ ។ ក្នុងការចែកប័ណ្ណពតិមាននេះ វាបង្កលក្ខណៈងាយស្រួល ដល់អ្នកបោះឆ្នោតបានកាន់តែឆាប់បើមានទិន្នន័យនៅក្នុងនោះត្រឹមត្រូវ ។ ចំពោះមតិដែលថា ឃុំខ្លះធ្វើត្រូវ ខ្លះមិនត្រូវ គឺដោយសារ លោកមេឃុំ ឬ សមាជិកក្រុមប្រឹក្សាឃុំ យកពេលនោះពិនិត្យបញ្ជីឈ្មោះដែរ ។ ដូច្នេះសំណូមពរទៅអង្គប្រជុំ និងមេឃុំ ក្នុងពេលនោះដែរថា នេះជាឱកាសដែលត្រូវចែកជូនឱ្យដល់ដៃទាំងអស់គ្នា កុំអាលពិនិត្យបើពិនិត្យត្រូវណែនាំឱ្យពលរដ្ឋ ពិនិត្យជាមួយអត្តសញ្ញាណណាមួយរបស់គាត់ ដើម្បីយកទៅកែតំរូវតាមថ្ងៃកំណត់ ។

ចំពោះការផ្លាស់ប្តូរការិយាល័យ បើមានការផ្លាស់ប្តូរលំនៅ ត្រូវទៅសុំចុះឈ្មោះបោះឆ្នោតនៅកន្លែងថ្មី ដើម្បីឱ្យគេចេញបង្កាន់ដៃមួយឱ្យយកទៅលុបនៅកន្លែងចាស់ ។ បើសិនទីតាំងស្ថានភាពការិយាល័យចាស់ មិនអាចប្រព្រឹត្តទៅបាន ដោយសារកន្លែងខ្លះពិបាករកទីតាំងចត លោកបានបញ្ជាមេឃុំ រកមួយថ្មីឱ្យបាន ត្រូវចៀសពីផ្ទះប្រជាជន និងត្រូវរកអគារសាធារណៈណាមួយឱ្យបាន ហើយឃុំ ភូមិក៏មានភារកិច្ចផ្សព្វផ្សាយ និងបិទផ្សាយ បញ្ជីរាបជូនពលរដ្ឋ ។ ការដូរការិយាល័យ ត្រូវប្រកាសជាសាធារណៈ គឺមិនលួចលាក់ទេ ជួនកាលដោយទីតាំងនោះចាស់ទ្រុឌទ្រោម ត្រូវទៅរកសាលារៀន វត្តអារាម ដូច្នេះទីតាំងការិយាល័យបោះឆ្នោតតែងចល័ត ដែលតែងធ្វើដោយចំហ ។ ការចុះមិនទាន់មានទេ ឥឡូវនេះស្ថិតក្នុងដំណាក់កាល ចែកប័ណ្ណព័តិមាន ហើយអ្នកដែលមិនធ្លាប់ចុះឈ្មោះ ត្រូវរកឯកសារមួយក្នុងចំណោមឯកសារផ្លូវការទាំង ១០ ជាសំអាង រួចទៅជួបស្មៀន ឬក្រុមប្រឹក្សាឃុំ ចាប់ពីថ្ងៃទី ០១ -២០ តុលា ។

ចំពោះរឿងទំរង់ ១០១៨ គឺដោយសារច្បាប់កំណត់ថា ត្រូវមានរូបថត ២សន្លឹក ។ ចំពោះការិយាល័យដែលបាត់ឈ្មោះ ដែលបានរកឃើញ តាមការចែកប័ណ្ណពតិមានអ្នកបោះឆ្នោត តើដោយសារមិនបានទៅពិនិត្យ ដោយសារកំហុស គជប នាំឱ្យមានឈ្មោះស្ទួន ត្រូវមានសិទ្ធិតវ៉ាជាមួយក្រុម ប្រឹក្សាឃុំ និងស្មៀន នេះជាសារៈប្រយោជន៍របស់ប័ណ្ណព័តិមានអ្នកបោះឆ្នោត ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់បន្ថែមអំពីរឿងមេភូមិថា លោកបានចូលរួមប្រជុំក្នុងឋានៈជាអ្នកសំរបសំរួល ខប់សែល ជាមួយ UNDP ហើយនិងម្ចាស់ជំនួយទាំងអស់ដែលបានជួយដល់ គជប ក្នុងការរៀបចំការបោះឆ្នោតទាំងពីរខាងមុខនេះ ។ រឿងមេភូមិនេះគ្មានអ្វីត្រូវតវ៉ាទៀតទេព្រោះអង្គរក្លាយជាបាយយើងមានតែការទទួលប៉ុណ្ណឹងឯង  ក៏ប៉ុន្តែមានមេភូមិច្រើនណាស់ដែលលោកធ្វើការដោយស្មោះលោកធ្វើការក្នុងឋានៈលោកជាមេភូមិ ជាតំណាងរាជរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាននោះ ហើយលោកធ្វើការបំរើពលរដ្ឋយ៉ាងពិតប្រាកដ  តែនៅមានមេភូមិមួយចំនួនលោកនៅធ្វើការក្នុងបំណងផ្ទាល់ខ្លួនខ្លះដែរនៅក្នុងរឿងនេះ ។ ដូច្នេះលោកគ្រាន់តែចង់ជម្រាបថា ក្នុងការប្រជុំទាំងពីរដងសហគមន៍អន្តរជាតិលោកបានសួរចំនុចពីរ ចំនុចទី ១ លោកសួរថា មេភូមិក្នុងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ គឺដរាបណាគាត់នៅមានសុខភាពល្អ គឺគាត់នៅធ្វើជាមេភូមិរហូត ប្តូរគាត់ចេញ លុះណាតែមេភូមិនោះអសមត្ថភាព ឬឈឺថ្កាត់ដែលមិនអាចបំពេញភារកិច្ចបាន ។ ដូច្នេះលោកសង្កេតឃើញថា ពេលលោកចុះទៅធ្វើការតាមមូលដ្ឋាន មេឃុំមិនសូវក្តាប់ពលរដ្ឋបានដូចមេភូមិទេ មេភូមិអាចដឹងរឿងច្រើនជាងគេទាំងអស់ក្នុងរឿងអភិវឌ្ឍន៍សេដ្ឋកិច្ច សុខភាព អប់រំ មេភូមិជាចលករខ្លាំងណាស់ ពលរដ្ឋមកជួបជុំគ្នាទទួលដំណឹងនៅផ្ទះមេភូមិ ។ បើចាត់តាំងមេភូមិរាប់ម៉ឺននាក់មិនត្រឹមត្រូវអាចធ្វើឱ្យមូលដ្ឋានមានបញ្ហា ។ លោកបានលើកជាមតិថា ដើម្បីជួយផ្តល់ពតិមានដល់មេភូមិ ឬ ស្ថាប័នភូមិ អំពីប័ណ្ណព័តិមានអ្នកបោះឆ្នោតដែល គជប បង្កើតឡើងបានបង្ហាញឱ្យឃើញថា អ្នកណាដែលធ្វើការល្អ និងអ្នកណាខ្លះដែលធ្វើការមិនល្អដើម្បីយើងកែតំរូវ ។ លោកស្នើឱ្យសង្គមស៊ីវិលខ្លះដែលនិយាយថា មានមេភូមិខ្លះចែកប័ណ្ណព័តិមានមិនបានទាំងអស់គ្នាដោយមានប្រកាន់និន្នាការ ហើយមេភូមិខ្លះធ្វើការបានល្អណាស់ នរណាក៏គាត់ចែកឱ្យដែរ ឱ្យរាយការណ៍ជូនអង្គប្រជុំស្តាប់ និងដឹងលឺទាំងអស់គ្នាដើម្បីកត់ត្រានៅក្នុងកំណត់ហេតុប្រជុំជាផ្លូវការ និងដើម្បីកែតំរូវមេភូមិនោះ ។ ដូច្នេះការដែលបានផ្សព្វផ្សាយចំណុចណាមួយ ឈ្មោះភូមិ ឈ្មោះមេឃុំ ធ្វើមិនត្រូវយ៉ាងណា ដែលមានចុះផ្សាយក្នុងកំណត់

ហេតុនេះហើយ ដែលយើងបានកែតំរូវ មិនឱ្យធ្វើបែបនោះទៀត ព្រោះគាត់កាន់តួនាទីនេះ សឹងតែមួយជីវិត លើកលែងតែមានការកែទំរង់ច្បាប់នោះ ។

លោកស្រី **ទេព ផល្លា** ជំនួយការ អង្គការ **AMK** លោកស្រីនៅឈរជាចំណុចកណ្តាល ដែលបានស្តាប់ និងយល់ថា ក្នុងការបោះឆ្នោត គឺយកអត្តសញ្ញាណប័ណ្ណជាគោល និងការចែកប័ណ្ណពតិមានអ្នកបោះឆ្នោត គឺសំរាប់ផ្តល់ពតិមានដល់ពលរដ្ឋផ្ទៀងផ្ទាត់ជាមួយគ្នា ។ តាមបទពិសោធន៏ឃើញថា ការសរសេរទិន្នន័យនៅប័ណ្ណសំគាល់នានាខុសៗគ្នា បើមានការសុំដូរទិន្នន័យផ្សេងៗក្នុងអត្តសញ្ញាណប័ណ្ណឱ្យត្រឹមត្រូវ តើមានគិតលុយឬអត់? ដោយសារពលរដ្ឋខ្លះ មិនចេះអក្សរ និងមិនដឹង យកអ្វីទៅផ្ទៀងផ្ទាត់ជាមួយប័ណ្ណពតិមាន ជួនកាលផ្ទៀងជាមួយប័ណ្ណបោះឆ្នោតចាស់ ឬប័ណ្ណផ្សេងៗទៀតបើមានអ្នកដឹង ទើបយល់ថា យកឯកសារណាមួយមកផ្ទៀង ។ លោកស្រី សំណូមពរថា បើបាប់ផ្តើមចែកប័ណ្ណព័តិមានហើយ សុំផ្ទៀងហើយគូសចំណាំផង ដើម្បីឱ្យដឹងថាប័ណ្ណនេះខុស ឬ ត្រូវ ព្រោះពលរដ្ឋច្រើនយកទៅទុកចោលតែម្តង មិនបានទៅជួបអ្នកណាទៀតទេ ហើយណែនាំឱ្យទៅជួប អ្នកនេះ អ្នកនោះដើម្បីកែ ។

លោកវីរៈសេនីឯក **ហែន វុទ្ធា** លោកឆ្លើយតបទាក់ទិននឹងការចង់ប្តូរឈ្មោះ និងទិន្នន័យផ្សេងៗ នៅក្នុងអត្តសញ្ញាណប័ណ្ណ ដើម្បីតំរូវតាមភាពជាក់ស្តែង ជាលើកទី ២ ។ ការធ្វើអត្តសញ្ញាណប័ណ្ណនេះ គឺម្នាក់ធ្វើបានតែម្តងទេ ដែលរដ្ឋាភិបាលបង់ថ្លៃចំណាយផ្សេងៗតាមអនុក្រឹត្យលេខ ៣៦ ដែលមានអមដោយប្រកាស លេខ ៤៨៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើអត្តសញ្ញាណប័ណ្ណឡើងវិញ ដោយភ្ជាប់អត្តសញ្ញាណប័ណ្ណចាស់ និងសំណើកែតំរូវទៅវិញផង ។ ការធ្វើអត្តសញ្ញាណប័ណ្ណលើកទី២ សាមីខ្លួនជាអ្នកចេញថវិកា ទ្វេដងដោយខ្លួនឯង ហើយនឹងបញ្ជូនចេញជាសមូហភាព ។ ធម្មតាអ្នកដែលចង់ដូរ តែងចង់បានឆាប់ និងបានឱ្យលុយមន្ត្រីប៉ូលីសច្រើន រហូតដល់ ៦០.០០០៛ គួបនឹងសោហ៊ុយនានាផង ។

លោក **ឱក សេរី សោភក្តិ** បានបញ្ជាក់បន្ថែមលើករណីនេះថា ករណីដែលកើតមាននៅក្រុងប៉ៃលិនល្អណាស់ អង្គប្រជុំបានចោទលោកស្នងការថា បានយកលុយ ៥០.០០០៛ ពីពលរដ្ឋនៅពេលធ្វើអត្តសញ្ញាណប័ណ្ណ ឬ កែតំរូវ ដែលចោទថានេះជាអំពើពុករលួយ តែរដ្ឋប្រកាសថា មិនយកលុយទេ ។ មើលទៅករណីនេះ ហាក់ដូចជាបែបនេះមែន ដូចបានលើកនៅក្នុងអង្គប្រជុំជាក់ស្តែង ។ លោកស្នងការនៅក្រុងប៉ៃលិនឆ្លើយថា លោកពិតជាយកមែន ៥០០.០០៛ តែពលរដ្ឋត្រូវមានការទទួលខុសត្រូវដូចអាជ្ញាធរដែរ ។ ពលរដ្ឋនៅពេលផ្តល់ពតិមាន ត្រូវមានការទទួលខុសត្រូវលើពតិមានដែលត្រូវ បើស្មៀនឃុំ សរសេរខុស ស្មៀនត្រូវទទួលខុសត្រូវក្នុងរឿងសរសេរខុស ហើយបើឱ្យលោកមន្ត្រីប៉ូលីសធ្វើ គាត់ត្រូវជិះតាក់ស៊ីទៅយកឯកសារដើមនៅភ្នំពេញ រដ្ឋមិនបានចេញសោហ៊ុយជូនក្នុងរឿងនេះទេ បើមិនទារលុយពីអ្នកធ្វើ តើមានលុយឯណាមករត់ការរឿងនេះ ។ គាត់ត្រូវចំណាយដល់ទៅ ៩០.០០០៛ ជាក់ស្តែង ដើម្បីធ្វើអត្តសញ្ញាណប័ណ្ណនេះ បានតំលៃ ៥០.០០០៛ ជាតំលៃថោកស្រាប់ហើយ ។ ដូច្នេះលោកស្នងការឆ្លើយថា ពិតជាយក ៥០០០០៛ មែន តែបានបញ្ជាក់ពីចំណាយលើចំនួននេះ ប្រើលើអ្វីខ្លះ ។ ជិះតាក់ស៊ីទៅមក ថ្លៃបាយស្ទើរមិនគ្រប់ផង ។ នៅពេលយើងចោទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ យើងជាពលរដ្ឋត្រូវពិនិត្យលើខ្លួនឯងដែរ តើការទទួលខុសត្រូវរបស់ខ្លួនជាពលរដ្ឋនៅកំរិតណា? មិនអាចម្ខាងណាទទួលខុសត្រូវម្នាក់ឯងទេ ត្រូវទទួលខុសត្រូវទាំងអស់គ្នា ។ លោកសូមសំដែងការគោរព និងកោតសរសើរចំពោះអស់លោក លោកស្រី ជាតំណាងសង្គមស៊ីវិលនៅកម្ពុជាដែលបានជួយច្រើនណាស់ដល់ការងារនេះមានតែអស់លោក លោកស្រីនេះហើយដែលចុះទៅជួយពលរដ្ឋតាមភូមិឃុំផ្ទាល់ ហើយនៅក្នុងការបោះឆ្នោតខាងមុខ គជប គខប ធ្វើមិនបានសព្វគ្រប់ទេ ទាល់តែគណបក្សនយោបាយដែលមានសមាជិក អង្គការសង្គមស៊ីវិល

ដូចដែលនៅខេត្តបាត់ដំបង ដែលស្នើថាសុំឱ្យយកវត្តអារាម ធ្វើជាចលករ ព្រោះមានមីក្រូច្រើនណាស់ មានកម្មវិធីបុណ្យច្រើន បើសិនយកមីក្រូផ្សព្វផ្សាយដំណឹងដល់ប្រជាពលរដ្ឋគួបនឹងភាពបរិសុទ្ធ នឹងប្រព្រឹត្តទៅដោយសន្តិវិធី ហើយបានទទួលដំណឹងច្រើនទៀត នៅពេលលោកចុះធ្វើការ សិស្សានុសិស្សថា បើសិន គខប ត្រូវការគេនឹងអាចជួយការងារនេះដោយស្ម័គ្រចិត្ត ដើម្បីផ្សព្វផ្សាយពត៌មានដល់ភូមិ ឃុំ ចំណាយតិចហើយ មានប្រសិទ្ធភាព និងបានជួយអាជ្ញាធរមូលដ្ឋាន ផ្តល់សេវាដល់ ពលរដ្ឋដោយបើកចំហ ។

ដូច្នេះសុំពិចារណាលើធនធានដែលមានស្រាប់ បើអស់លទ្ធភាពហើយឬនៅ ក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើងកន្លងមកនេះ ហើយនៅផ្លូវផ្តងករណីដែលបានលើកឡើងនៅប៉ៃលិន ខេត្តបាត់ដំបង ឃើញថា ធនធានយើងនៅមានច្រើន បើចេះរួបរួមគ្នាដោយស្មោះ ឆ្លើយឆ្លងគ្នាដោយស្មោះ អ្នកកាន់អំណាចឆ្លើយដោយទៀងត្រង់ដែរ ដូច្នេះយើងអាចរកមធ្យោបាយដោះស្រាយ និងធ្វើការរួមគ្នាបាន ។ អ្វីដែលលើកឡើងនេះ គឺដើម្បីចែករំលែកបទពិសោធន៍ ដែលអាចបំភ្លឺផ្លូវខ្លះអាចធ្វើការកែលំអបាន ។ លោកក៏បានអរគុណដល់លោកស្រីខាង **AMK** ដែលបានលើកឡើងលើករណីជាក់ស្តែង ព្រោះបានចុះធ្វើការផ្ទាល់នៅតាមមូលដ្ឋាននានា និងបានដឹងពត៌មានច្រើន ហើយបានចែកពត៌មាននេះដល់អង្គប្រជុំ ។

លោក **នួន សន** ជំទប់ទី ២ ឃុំសំរោង គណបក្ស សមរង្ស៊ី លោកបានលើកឡើងថា បញ្ជីផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោត នៅក្នុងឃុំ ដែលលោកជាតំណាងឱ្យក្រុមប្រឹក្សាឃុំ បានចុះទៅតាមមូលដ្ឋាននៃភូមិអូហេង និងភូមិសំរោង ១ ធ្វើការចែកចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត បានតែ១៧៥នាក់ ដែលក្នុងភូមិនីមួយៗមាន ៣៥០នាក់ ។ ដូចនេះ ឃើញថានៅបាត់ ពលរដ្ឋជាងពាក់កណ្តាល ។ លោកបានសំណូមពរលើបញ្ហាមេភូមិអង្គ្រង ដែលមានបញ្ហាជាមួយពលរដ្ឋ និងជាមួយតំណាងគណបក្សសម រង្ស៊ីនៅឃុំនេះ លោកមេភូមិនោះបានគំរាមពលរដ្ឋថា អ្នកណាចូលជាមួយគណបក្ស សម រង្ស៊ី មិនបានទេ ដែលនេះបង្កឱ្យមានការភ័យខ្លាចដល់ពលរដ្ឋនៅមូលដ្ឋាននេះ ក្រែងមានគ្រោះអ្វីកើតឡើង ដូច្នេះសុំស្នើអង្គការនានាជួយអប់រំ និងពន្យល់ដល់ភូមិទាំងឡាយដែលកើតមានបញ្ហាបែបនេះកើតឡើង ។

លោក **ផាន់ វណ្ណសិទ្ធិ** ដោយសារមានក្រដាសចម្ងល់ពីលោកសមាជិកអង្គពិធី ដែលលើកឡើងថា ចំពោះអត្តសញ្ញាណប័ណ្ណ ឬបញ្ជីបោះឆ្នោតដែលមានឆ្នាំកំណើត និងក្នុងប័ណ្ណខ្លះមានទាំងថ្ងៃខែឆ្នាំកំណើត នេះមិនចោទជាបញ្ហាអ្វីទេ ។ ក្រោយមកមានលោកបានចំណាប់អារម្មណ៍ទូទៅលើការងារ និងករណីនានាដែលបានលើកបង្ហាញនៅខេត្តពោធិ៍សាត់ព្រឹកនេះ គឺក្នុងន័យជាប្រវត្តិសាស្ត្រ ដែលបានកសាងថ្នាលបណ្តុះពូជ វប្បធម៌ថ្មី ដែលទាំងអស់គ្នា មានឱកាសនិយាយដោយចំហ នៅទល់មុខគ្នា ដែលមានអ្នកពាក់ព័ន្ធនឹងការងារបោះឆ្នោតចំរុះចូលរួម ដូចជាអាជ្ញាធររៀបចំការបោះឆ្នោត អាជ្ញាធរដែនដី គណបក្សនយោបាយ អង្គការសង្គមស៊ីវិល ។ ក្នុងការងារដែលយើងផ្តោតសំខាន់ថ្ងៃនេះ គឺការងារបោះឆ្នោត ។ អ្វីដែលបាន ធ្វើកន្លងមក ៤-៥ ដងហើយនោះ តែងមានបញ្ហាជាបន្តបន្ទាប់ តែពីដំណាក់កាលមួយទៅមួយទទួលបានវិជ្ជមានច្រើនជាង និងនៅមានកង្វះខាតខ្លះដែលនៅមិនទាន់ដោះស្រាយ និងបានព្យាករណ៍ទុកពីអ្វីដែលនឹងអាចកើតមានឡើង នេះជាការប្រមូលផ្តុំកំលាំងដ៏ធំមួយ ហើយវេទិកានេះក៏ជាឱកាស មួយដែលអនុញ្ញាតឱ្យយើងស្គាល់គ្នា និងបានផ្លាស់ប្តូរយោបល់ជាមួយគ្នា ហើយសង្ឃឹមថា រាល់កិច្ចការទាំងអស់នៅពេលខាងមុខ នឹងទទួលបានជោគជ័យច្រើនជាងបណ្តាឆ្នាំកន្លងមក ដោយបញ្ចៀសបាននូវបាតុភូត និងកង្វះខាតផ្សេងៗ និងមិនអាចលទ្ធផលវិជ្ជមាន ១០០% ទេ តែបើយើងហ៊ាន និយាយដោយស្មោះត្រង់ និងហ៊ានចង្អុលបញ្ជាក់ ហើយគិតគូរឱ្យបានត្រឹមត្រូវ យើងនឹងរកឃើញដំណោះស្រាយ ។

ដូច្នេះការលោកញ្ចប់បញ្ហាដាក់លើតុមើល និយាយទាំងអស់គ្នា លោកជឿថាអ្វីក៏អាចដោះស្រាយបានដែរ និងចៀសផុតពីអំពើហិង្សា ការចោទប្រកាន់មូលបង្កាច់ ហើយផ្សព្វផ្សាយធ្វើឱ្យខាតពេលក្នុងការប្រតិបត្តិការ ។ ក្នុងដំណាក់កាលមួយៗយើងមានពេលវេលា

ពិតប្រាកដណាស់ ចុះឈ្មោះ ចុះបញ្ជីគណបក្សនយោបាយ ឃោសនាបោះឆ្នោត ៨ម៉ោង បើយកពេលនេះទៅហែកហួរ មិនព្រមឈរជជែកគ្នា នឹងអស់ពេលធ្វើការ ។ លោកមានភ័ព្វសំណាស់ដោយបានមកចូលរួមស្តាប់ ជួបជុំគ្នា និយាយគ្នាផ្ទាល់នៅក្នុងវេទិកានេះ ហើយសូមឱ្យដំណើរការនេះ មានជាបន្តបន្ទាប់នៅតាមខេត្ត និងតាមបែបវិសាមញ្ញទៅកាន់តំបន់  ស្រុក គោលដៅណាមួយ ធ្វើថ្នាលពិសោធន៍នោះជាការល្អ ។

លោក **ឡារី ស្ត្រេន្ទ** សូមថ្លែងអំណរគុណចំពោះលោក សោភក្តិ និងលោកប្រធាន គជបខ ដែលបានធ្វើបញ្ចប់ដ៏មានខ្លឹមសារ ។ រាល់ពេល លោក សោភក្តិ សំណូមពរឱ្យធ្វើការសង្ខេបសរុបនៅក្នុងពេលប្រជុំនីមួយៗ ដែលនេះជាការលំបាកណាស់ក្នុងការសន្និដ្ឋានសរុបក្នុងពេលដ៏ខ្លីនូវអ្វីដែលលោក  លោកស្រី  បានលើកឡើង  ហើយដែលសុទ្ធតែមានសារៈសំខាន់ៗទាក់ទិននឹងការបារម្ភណ៍របស់លោកលោកស្រី ។ លោកបានកត់សំគាល់ ចំណុចសំខាន់ ៤ ដែលលោក លោកស្រី បានលើងឡើងនៅពេលព្រឹកនេះគឺ ១. អ្វីដែលបានលើកឡើងគឺជាសារដ៏សំខាន់មួយដែលបានបង្ហាញសុទ្ធតែ ទាក់ទងនឹងការងារបោះឆ្នោត ដែលមានតាំងពីឆ្នាំ១៩៩៣ រហូតមកដល់ពេលនេះ មានដំណាក់កាលជាច្រើន  ហើយកាដែលលើកឡើងនេះ  គឺបានបង្ហាញពីភាពរីកចំរើនជាបណ្តើរៗ  នៅក្នុងការងារនេះ  ទាំងគុណភាពនិងផ្នែកបច្ចេកទេស ។ ទន្ទឹមនេះ យើងក៏បានឯកភាពគ្នាជារួមថា ទោះជាមានការរីកចំរើនច្រើនហើយក្តី ក៏នៅតែមានកិច្ចការច្រើនត្រូវធ្វើបន្តទៀតដែរ ដើម្បីបំរើឱ្យការងារបោះឆ្នោតនេះកាន់តែប្រសើរជាងនេះទៀត ។ យើងក៏បានឃើញពីការបញ្ជាក់បន្ថែមទៅលើ បញ្ហាអត្តសញ្ញាណប័ណ្ណជាតិ  និងបានស្តាប់របាយការណ៍របស់លោកស្នងការទាក់ទិននឹងការវិវត្តន៍នានាជុំវិញការងារនេះ  និងបានដឹងពីដំណើរនេះថា នឹងសំរេចឱ្យបានទាំងអស់គ្នាក្នុងដំណាច់ឆ្នាំនេះ ។ លោក  លោស្រីក៏បានលើកពីការព្រួយពីការចែកប័ណ្ណព័តិមាន ដែលនេះជាចំណុចសំខាន់ណាស់  ដែលយើងគួរធ្វើយ៉ាងណាឱ្យដំណើរការរលូនល្អ  ហើយប័ណ្ណព័តិមានបានដល់ដៃពលរដ្ឋទាំងអស់គ្នាប្រកប  ដោយប្រសិទ្ធិភាពនៅតាមមូលដ្ឋាន  ។ នៅមានខ្លឹមសារសំខាន់ពីរទៀតគឺបរិយាកាសដែលគ្មានការរើសអើង  ការរុកគួននានាក្នុងចំណោមអ្នកបោះឆ្នោត និងសេរីភាពក្នុងការជ្រើសរើសតំណាងគណបក្សនយោបាយនានាដែលពលរដ្ឋពេញចិត្ត ព្រមទាំងបានស្តាប់ពីការទទួលខុសត្រូវរបស់ តំណាងគណបក្សនយោបាយដើម្បីធានាការងារនេះឱ្យចប់សព្វគ្រប់ និងប្រព្រឹត្តទៅបានល្អ ។ មួយទៀតអំពីការចែករំលែកពតិមានគ្នាទៅវិញទៅមកក្នុងចំណោមមន្ត្រី គជប អាជ្ញាធរដែនដី និងនៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យប័ណ្ណពតិមាន និងពតិមាននានា ដើម្បីឱ្យមានតម្លាភាព និងការអនុវត្តការងារ ដើម្បីឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការរៀបចំការបោះឆ្នោត ។

ចំណុចចុងក្រោយ  ដែលជាទស្សនៈផ្ទាល់ខ្លួន  ក្នុងនាមលោកជាជនបរទេសដែលទើបមកធ្វើការនៅកម្ពុជាបានជាង២ឆ្នាំ  ។ លោកមកពីប្រទេសអូស្ត្រាលី ជាប្រទេសទើបមានអាយុកាលជាង ១០០ឆ្នាំ គឺជាប្រទេសមួយដែលអនុវត្ត និងប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យមួយដ៏រឹងមាំ និងទទួលបាននូវការគោរពពីគ្រប់ភាគីពាក់ព័ន្ធនានា ។ មុននឹងយើងទទួលបាននូវលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំនេះទាមទារពេលយូរអង្វែង ច្រើនដំណាក់ និងច្រើនទសវត្សរ៍ ។ ជោគជ័យដែលទទួលបាន គឺអាស្រ័យដោយកិច្ចសហការ និងការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងប្រទេសអូស្ត្រាលី ពិសេសអ្នកដឹកនាំគណបក្សនយោបាយ អង្គការសង្គមស៊ីវិល អាជ្ញាធរ សហគមន៍សារពតិមាន  និងពលរដ្ឋទាំងអស់  ដើម្បីជំរុញដំណើរការកសាងលទ្ធិប្រជាធិបតេយ្យមួយដ៏ខ្លាំងក្លា  ។ លោកលើកឡើងពីបទពិសោធន៍នេះដើម្បីរួមចំណែកបង្ហាញជូនលោក  លោកស្រី  គឺការកសាងលទ្ធិប្រជាធិបតេយ្យ  និងសូមកោតសរសើរ  ចំពោះការចូលរួមរបស់លោកលោកស្រី ដែលបានលើកឡើងនូវមតិនានា ជុំវិញការងារបោះឆ្នោតដើម្បីជាដំណើរមួយជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងដើម្បីកែលំអដំណើរការរៀបចំការបោះឆ្នោត ឱ្យទទួលបានជោគជ័យល្អប្រសើរ ។

នៅទីបញ្ចប់លោកបានអរគុណដល់ការចូលរួមរបស់លោក លោកស្រី យ៉ាងសកម្មក្នុងពេលនេះ និងសូមអរគុណដល់ ឯ.ឧ. អភិបាលខេត្ត និង អភិបាលរងទី ១ លោកប្រធាន គជបខ ស្នងការខេត្ត លោក ឌិក សេរី សោភក្តិ៍ និងក្រុមការងារ ឧប់សែល និងលោក លោកស្រីទាំងអស់ដែល បង្កឱ្យបរិយាកាសនៃកិច្ចប្រជុំនេះប្រព្រឹត្តទៅបាន ។

លោក **ឌិក សេរី សោភក្តិ៍** មុននឹងជំរាបលា លោកនៅមានចំណុចមួយដែលចង់បញ្ជាក់គឺ ការទទួលខុសត្រូវ ។ ក្នុងពេលយុទ្ធនាការឃោសនា និងរាប់សន្លឹកឆ្នោត តួអង្គអ្នកសង្កេតការណ៍គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលមានសារៈសំខាន់ណាស់ ។ នៅពេលកំពុងយុទ្ធនាការឃោសនាក្តៅគគុក សុំឱ្យបញ្ជោសរឿងទាំងឡាយណាដែលមិនទាក់ទិននឹងរឿងបោះឆ្នោត និងមានសេចក្តីក្លាហានថា រឿងនេះមិនទាក់ទងនឹងកាបោះឆ្នោតទេ បើយើងច្របល់រឿងនានាបញ្ចូលគ្នា ស្ថានការណ៍នានានៅក្នុងខេត្ត អាចគ្រប់គ្រងមិនបាន ដូចនេះការទទួលខុសត្រូវរបស់អាជ្ញាធរ និងអង្គការសង្គមស៊ីវិលដែលរួមគ្នាក្តាប់ស្ថានការណ៍នេះ ។ នៅពេលរាប់សន្លឹកឆ្នោត សុំឱ្យតំណាងគណបក្សនយោបាយកុំអាលទៅណា កុំអាលដើរចេញពីការិយាល័យបោះឆ្នោត ទោះដឹងលទ្ធផលហើយក៏ដោយ សូមចាំចុះហត្ថលេខាលើទំរង់បែបបទនានាឱ្យចប់សិន ។ លទ្ធផល និងតួនាទី សូមចែកឱ្យដាច់ ត្រូវចាំចុះហត្ថលេខាទទួលស្គាល់សិន គឺជាការទទួខុសត្រូវទាំងអស់គ្នា ។ នេះជាភាពចាស់ទុំនៅក្នុងលទ្ធិប្រជាធិបតេយ្យ ។ សូមកោតស្ញប់ស្ញែងដល់ការចូលរួម និងភាពថ្មៃថ្នូររបស់លោក លោកស្រី នៅក្នុងខេត្តពោធិសាត់នេះ និងការលើកបញ្ហានានាជុំវិញការងារបោះឆ្នោតក្តៅៗបានទាំងអស់ ដោយប្រើពេលខ្លីជាងខេត្តណាៗទាំងអស់ លោកប្រធាន គខប មានប្រសាសន៍ថ្លៃថ្លាណាស់ពីវប្បធមិក្នុងការពិភាក្សាជជែកគ្នា និងស្នើឱ្យមាន យន្តការពិសេសនៅថ្នាក់ ឃុំ បើអាចធ្វើបាន ។

លោកបានទទួលសំណើរ និងពិចារណាលើការអនុវត្តន៍ជាក់ស្តែងបានដល់ និងជួបការលំបាកក៏រិតណា ។ នៅចុងបញ្ចប់សូមបួងសួង គុណបុណ្យព្រះរតនត្រៃយ៍ និងទេវតាទាំងមួយម៉ឺនលោកធាតុ ទេវតាថែរក្សាស្វេតឆ័ត្រ និងទឹកដីខេត្តពោធិសាត់ ព្រលឹងអ្នកតាឃ្លាំងមឿង សូមជួយថែរក្សា លោក លោកស្រីទាំងអស់ឱ្យប្រកបតែសេចក្តីសុខ សុខភាពបរិបូណ៌ និងសូមឱ្យស្មារតីនៃសហប្រតិបត្តិការបានល្អ ដើម្បីរៀបចំការបោះឆ្នោតឆ្នាំ២០០៧-២០០៨ បានជោគជ័យប្រកបដោយសុវត្ថិភាព ។